ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2013, 09:11
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី១៥៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក  គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តការធ្វើសវនាការការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានា ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ដែលនឹងដាក់ដោយតំណាងសហព្រះរាជអាជ្ញាបញ្ចប់។ ហើយនីតិវិធីបន្តបន្ទាប់គឺការធ្វើអត្ថាធិប្បាយបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងប្រធានបទនេះ និងការធ្វើអត្ថាធិប្បាយ ឬក៏ការឆ្លើយ -- ការជំទាស់របស់ក្រុមមេធាវីការពារក្តីលោក អៀង សារី និងលោក ខៀវ សំផន ចំពោះឯកសារដែលតំណាងសហព្រះរាជអាជ្ញាបានដាក់ចំពោះអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ។

លោក ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

[០៩:០៧:១២]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់ថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ នួន ជា អវត្តមានដោយមូលហេតុសុខភាព តែជនជាប់ចោទបានលះបង់សិទ្ធិមានវត្តមានសម្រាប់សវនាការលើកឯកសារ។

ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តីលោក នួន ជា កាលពីរសៀលថ្ងៃ៣១ ខែមករា ឆ្នាំ២០១៣ កន្លងទៅនេះអង្គជំនុំជម្រះបានសាកសួរទៅក្រុមមេធាវីការពារក្តីអំពីជំហររបស់លោក នួន ជា នៅក្នុងការចូលរួមឬមិន

ចូលរួមលះបង់សិទ្ធិក្នុងចូលរួមស្តាប់សក្ខីកម្មសាក្សី TCW-100 ហើយនិង/ឬ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-116 តើបានលទ្ធផលយ៉ាងម៉េចដែរ?

[០៩:០៨:៣៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវី ភាគីទាំងអស់។ ដូចដែលលោកប្រធានបានជ្រាបហើយ កូនក្តីរបស់ខ្ញុំបានចេញពីមន្ទីរពេទ្យកាលពីថ្ងៃព្រហស្បតិ៍អាទិត្យ ប៉ុន្តែជាអកុសល គឺថាពេលយប់ទេកាលណោះ ហើយយើងខ្ញុំបានជួបគាត់ ហើយពេលនោះយើងអាចនឹងជម្រាបកូនក្តីរបស់ខ្ញុំពីម្សិលមិញនេះតែប៉ុណ្ណោះ។ គាត់បានតែនាំយើងខ្ញុំថា ហើយគាត់ចុះហត្ថលេខាលើការលះបង់សិទ្ធិ ហើយចៅក្រមអាចបន្តស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន។ ប៉ុន្តែគាត់មិនលះបង់សិទ្ធិក្នុងការវត្តមាន ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីដែលបានស្នើនោះទេ។

លោកប្រធានអាចចាប់ផ្តើមជាមួយដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមិនអាចចាប់ផ្តើមសវនាការជាមួយនឹងសាក្សីរបស់សហព្រះរាជអាជ្ញានោះបានទេ ព្រោះគាត់មិនបោះបង់សិទ្ធិបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវព័ត៌មានជាក់ច្បាស់នេះ។

បាទជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានា ដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន។

[០៩:១០:២៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ហើយនិងភាគីមេធាវីការពារទាំងអស់ និងសាធារណជន។ ដូចដែលលោកចៅក្រមបានជ្រាបមកហើយថា យើងបានពិនិត្យមើលនូវសៀវភៅមួយដែលនិពន្ធដោយលោក ខៀវ សំផន មុនពេលដែលយើងបានសម្រាកក្រោយពីវគ្គ -- បន្ទាប់ពីវគ្គចុងក្រោយនោះ គឺយើងបានពិភាក្សាបន្តិច។ ឥឡូវនេះ ខ្ញុំត្រឡប់ទៅសៀវភៅនោះឡើងវិញ ដែលយើងនឹងមើលផ្នែកពាក់ព័ន្ធមួយចំនួន។ ឯកសារនោះមានចំណងជើងថា “ការពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ” ដែលនិពន្ធដោយលោក ខៀវ សំផន។ ឯកសារ E3/16 ហើយយើងខ្ញុំបានដកស្រង់ចេញពីជំពូកទី៥ ហើយយើងខ្ញុំនឹងដកស្រង់ផ្នែកផ្សេងៗ

ទៀតពីជំពូកនេះ។

[០៩:១១:៤០]

ដើម្បីរំឭកដល់សាធារណជន លោកចៅក្រម អំពីអ្វីដែលយើងបានបញ្ចប់ពីមុននោះ គឺផ្នែកមួយដែលយើងបាន -- ខ្ញុំអានមុនពេលសម្រាកនោះ ហើយខ្ញុំនឹងអានឡើងវិញ ជាថ្មីឡើងវិញដើម្បីឲ្យយើងតភ្ជាប់សាច់រឿងពីមុន គឺនៅខ្មែរ ERN 00380454, បារាំង ERN 00643883 ហើយនិងអង់គ្លេស ERN 00498277 ផ្នែកដែលទាក់ទងទៅនឹងខ្លឹម -- អំពីការតាមដានរបស់ ប៉ុល ពត ទៅលើកម្មាភិបាលជាន់ខ្ពស់ដែលចោទថា ជាជនក្បត់នោះសូមដកស្រង់ "ភស្តុតាងដែល ហ្វីលីព ស្បូត ផ្ដល់អំពីចលនាខ្មែររំដោះនោះរួមជាមួយភស្តុតាងផ្សេងទៀតដែល រួមទាំងភស្តុតាងផ្សេងទៀតដែល រួមទាំងការស្រាវជ្រាវផ្សេងទៀតដែលបានបញ្ជាក់ថា ការតាមដានទាំងនេះ ប៉ុល ពត នេះ គឺថាមានគោលការណ៍ 3878 របស់ចក្រី, ឈូក, យ៉ា ហើយនិងកម្មាភិបាលផ្សេងទៀត ដែលបានរួមជាមួយវៀតមិញ ជាគោលការណ៍នោះ គឺត្រឹមត្រូវ។ ដូច្នេះ ហ្វីលីព ស្បូត មិនត្រឹមត្រូវទេ ដែលគាត់សរសេរថា តួនាទីរបស់គុក ស-២១ ហើយនិងសេចក្ដីសារភាពមិនមែនសម្រាប់ផ្ដល់ព័ត៌មានជាសំខាន់នោះទេ គឺសម្រាប់តែផ្ដល់ភស្តុតាងនៃអំពើក្បត់ ដែលគេត្រូវការដើម្បីចាប់អ្នកណាដែលគេសម្រេចចាប់ទៅហើយនោះ។ គោលនយោបាយឯករាជ្យពីវៀតណាមនោះ តម្រូវឲ្យអនុវត្តនយោបាយដាច់ខាតនៅក្នុងប្រទេស"។

[០៩:១៣:៣៧]

ហើយយើងខ្ញុំផ្អាកត្រឹមខ្លឹមសារទាំងនេះ ហើយនឹងបន្តទៅទៀតខាងក្រោមបន្តិច នៅក្នុងផ្នែកនេះដែលខ្ញុំបានចាប់ផ្ដើមអានមុនពេលសម្រាកនោះ ខៀវ សំផន បានពិភាក្សាអំពីការប្រជុំសម្រេច អំពីការយល់ដឹង អំពីការពិភាក្សារបស់ ប៉ុល ពត អំពីចម្លើយសារភាពដែលបានស្រង់ចេញមកពីកម្មាភិបាលដែលជាប់សង្ស័យនោះ។ ហើយខ្ញុំមិនអានឯកសារនេះទាំងស្រុងនោះទេ មិនយកខ្លឹមសារនៃចម្លើយសារភាពទេ ក៏ប៉ុន្តែខ្ញុំពិនិត្យមើលតែអ្វីជាយោបល់របស់ ប៉ុល ពត ទាក់ទងទៅនឹងការដឹងរបស់ប៉ុល ពត និង ខៀវ សំផន នូវខ្លឹមសារនូវដំណើរការណោះ។ ខ្មែរ ERN 00380457 ដល់58 ខាងចុង, បារាំង ERN 00633885, អង់គ្លេស ERN 00498279 ដែលបានពិភាក្សាអំពីចម្លើយសារភាពរបស់ កុយ ធួន។ ចម្លើយទាំងអស់នេះចុះថ្ងៃ៤ ខែមីនា ឆ្នាំ១៩៧៧។ តាមខ្ញុំយល់ក្នុងចម្លើយនេះមានខ្លឹមសារសំខាន់ៗបីដែលអាចនាំឲ្យលោកប៉ុល ពត យកចិត្តទុកដាក់។

ខ្ញុំសូមចូលចំណុចនេះ គឺជាខ្លឹមសារដ៏វែង ខ្ញុំនឹងអានតែពីរចំណុចទេ ហើយចំណុចផ្សេងទៀតគឺ

មាននៅក្នុងឯកសារតុលាការ។

ចំណុចទី១ "សេចក្តីសារភាពនេះអាចនាំឲ្យប៉ុល ពត កាន់តែមានជំនឿថា លោកចាប់ខ្លួន យ៉ា មិនខុសទេ ហើយលោក យ៉ា អាចជាបុគ្គលមួយមានតួនាទីសំខាន់ក្នុងបក្សថ្មីដែលគេកំពុងរៀបចំ"។ លេខ២ "តែបញ្ហាដែលលោក ប៉ុល ពត អាចចាប់អារម្មណ៍ជាងអ្វីៗទាំងអស់ គឺទាក់ទងទៅនឹងសេចក្តីសារភាពរបស់ កុយ ធួន នេះគឺរឿងដែលលោក ឌឿន ប្រធានមន្ទីរ៨៧០ យកការណ៍សម្ងាត់របស់គណៈអចិន្ត្រៃយ៍គឺរឿង លោកវី និងលោកឡៅ ជាលេខា និងអនុលេខារតនគិរី រាយការណ៍ទៅលោក យ៉ា។ ក្រៅពី ឌឿន គ្មានអ្នកណាដឹងរឿងនេះទេ"។

[០៩:១៦:២៥]

មួយទំព័រខាងក្រោមទៀតនៅក្នុងបីភាសា នៅក្នុងហ្វូតណូត នៅក្នុងជើងទំព័រ១៩៣ ខៀវ សំផន បានពិភាក្សាអំពីកាលៈទេសៈរបស់ឌឿន ដែលថាការបាត់ខ្លួនរបស់ឌឿន ហើយចម្លើយបញ្ហានេះទាក់ទងថាតើគាត់ ខៀវ សំផន ខ្លួនឯងហ្នឹងជំនួស ឬក៏មិនជួស ឌឿន នៅក្នុងមន្ទីរ៨៧០។ នេះគឺជាអ្វីដែលគាត់បាននិយាយ។ សូមដកស្រង់ "មានមតិមួយចំនួនបន្ទាប់ពីគេចាប់ខ្លួន ឌឿន ទៅ ខ្ញុំបានឡើងធ្វើជាប្រធានមន្ទីរ៨៧០ ដែលថាអង្គហេតុនេះគឺមិនពិតទេ។ ខ្ញុំមិនដឹងថាអ្នកណាជា អ្នកណាដែលត្រូវបានចាត់តាំងជំនួស ឌឿន ទេ នេះជាការសម្ងាត់ខ្លាំងណាស់នៅពេលនោះ។ ទោះបីជាក្នុងអង្គភាពដដែលក៏ដោយ នៅក្នុងមន្ទីរ៨៧០ ក្តី ក៏តែងតែមានការសម្ងាត់ដដែល។ ខ្ញុំមិនចង់ដឹង ឬក៏ឮអ្វីនោះទេ អំពីអ្វី ឌឿន បានធ្វើ ឬក៏ ឌឿន ទៅណានោះទេ។ ដូច្នេះហើយគឺគាត់មិននៅក្នុងមន្ទីរនោះញឹកញាប់ទេ។ ប្រពន្ធរបស់ខ្ញុំគឺទទួលបន្ទុកឯចង្ក្រានបាយ ហើយគាត់ទុកបាយឲ្យគាត់នៅលើតុ។ ដោយសង្ខេបគឺថា ក្រោយមកគេមិនឃើញគាត់នោះទេ គឺថាយូរៗទៅហាក់ដូចជាស៊ាំនឹងសភាពការណ៍នេះហើយ។ លោក ឌឿន ទៅណាមកណាក៏មិនបានជាគិតនោះដែរ។ ដូច្នេះទាំងប្រពន្ធខ្ញុំ និងខ្ញុំមិនដឹងថា គេចាប់ខ្លួនផងទេ។ យើងគិតថាក៏មិនបានដឹងថា អ្នកណាទទួលការងារតពីគាត់នោះដែរ"។

[០៩:១៨:១៥]

ហើយក្នុងខណៈបន្ទាប់ទៅនេះ យើងនឹងពិនិត្យមើលសេចក្តីដកស្រង់អំពីចម្លើយ ដោយបុគ្គលផ្សេងៗទៀត ដែលដឹងអំពីមុខងាររបស់ថ្នាក់ដឹកនាំ ដែលអ្នកនោះមកជំនួស ឌឿន។ យើងមានផ្នែកមួយចំនួននៅក្នុងសៀវភៅនេះ ដែលយើងខ្ញុំចង់នឹងដកស្រង់ជូនតុលាការ និងភាគីស្តាប់។ ផ្នែកបន្ទាប់នោះគឺបញ្ជាក់ពីការបែងចែកអំពីការយកស្បៀងអាហារមកពីសហករណ៍ដោយគណៈមជ្ឈិម ហើយនិងទំនាក់

ទំនងរបស់វៀតណាម ហើយនិងការសង្ស័យអំពីវិទ្ធង្សនារបស់វៀតណាម។ នេះគឺជាខ្មែរ ERN 00380472 ដល់73, បារាំង ERN 00643894, អង់គ្លេស 00498287។ សូមដកស្រង់ "ការបង្អត់អាហារ ដើម្បីឲ្យដឹកស្បៀងអាហារទៅជូនរដ្ឋឲ្យបានគ្រប់គ្រាន់តាមកំណត់។ បញ្ហានេះដែលចោទទៀតគឺថាតើវៀតណាមចូលជ្រៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺក្នុងឆ្នាំ១៩៧៣ អាចចប់ឬនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៨ នោះ។ ទោះជាយ៉ាងណាក្តី ការជ្រួលច្របល់នៅពេលនោះ គឺជាកត្តារួមសំខាន់ នាំឲ្យកម្មាភិបាលល្អៗជាច្រើនដែលកន្លងមកស្មោះត្រង់ចំពោះបុព្វហេតុរហូត។ ហើយសកម្មភាពប្រយុទ្ធបែរទៅជាការរាថយ។ ការស្ទាក់ស្ទើររបស់គេចំពោះមុខសភាពការណ៍នេះ ក៏គួរឲ្យយើងយល់បានដែរ ប៉ុន្តែស្ថិតនៅក្នុងចំពោះមុខ ការប៉ុនប៉ងជាច្រើន ច្រើនសា មេដឹកនាំកុម្មុយនីស្តវៀតណាមឲ្យឱសានវាទដោយវៀតណាមនៅខែ ឧសភា ឆ្នាំ១៩៧៦ ដាក់មកលើកម្ពុជា បានជំរុញលោក ប៉ុល ពត និងក្រុមដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ឈានដល់សេចក្តីសន្និដ្ឋាន កម្មោចរនុកក្នុងរបស់វៀតណាមជាផ្លូវការមួយគត់ដើម្បីកម្ពុជារស់។ ខៀវ សំផន បន្ទាប់បាននិយាយអំពីបញ្ហា អំពីការជម្លៀសដោយបង្ខំ នៅក្នុងឆ្នាំ១៩៧៥ ហើយនិងការពិចារណាថា ដែលនាំឲ្យមានសេចក្តីសម្រេចជម្លៀសនោះ។ នៅទីនេះ គាត់បាននិយាយថា ជាពិសេសគឺ និយាយក្នុងការងារដែលសម្រេចពិចារណា។ ខ្មែរ ERN 00380493 រហូតដល់ 94, បារាំង ERN 00636439907 (ស៊ីក), អង់គ្លេស 004984 (ស៊ីក) បាទ ដូច្នេះនៅក្នុងសេចក្តីដកស្រង់គេបានចោទ ប្រកាន់ទៅលើ ប៉ុល ពត អំពីថាបានជម្លៀសប្រជាជនចេញពីទីក្រុង និងពីទីរួមខេត្ត តែនៅក្នុងការចោទ ប្រកាន់នេះ គេមិនបាននឹកដល់សភាពការណ៍លំបាក និងពោរពេញទៅដោយហិង្សាដែលរដ្ឋអំណាចក្មេង ខ្ចីត្រូវប្រឈមមុខនោះទេ។

[០៩:២២:២០]

នៅក្នុងកថាខណ្ឌមួយទៀត គាត់បាននិយាយដូចខាងក្រោមនេះ៖

"អ្វីដែលអាចនាំឲ្យមានគ្រោះថ្នាក់ធំដល់រដ្ឋអំណាចដ៏ក្មេងខ្ចី គឺសភាពការណ៍ដែលមានមនុស្សរាប់ម៉ឺននាក់បានស្លាប់រួចទៅហើយ ហើយមានអ្នកដែលកំពុងតែផ្តេតៗចាំតែស្លាប់បន្តបន្ទាប់គ្នានេះ។ ជាលក្ខណៈអនុគ្រោះណាស់ឲ្យភ្នាក់ងារ សេ.អ៊ី.អា ធ្វើវិទ្ធង្សនា ហើយរួមជាមួយសំណល់នៃកងទ័ពរបស់ លន់ នល់ ដែលច្បាស់ជានៅមានលាក់អាវុធនៅក្នុងទីក្រុង និងគ្រប់កន្លែងផ្សេងៗទៀតទូទាំងប្រទេស និងបង្កើតឲ្យមានការប៉ះបោរនៅភ្នំពេញ និងកន្លែងផ្សេងទៀតក្នុងប្រទេស។ គ្រោះថ្នាក់ធំជាងគេបំផុត គឺបះបោរ និងចលាចលទាំងនេះ នឹងបង្កជាឱកាសឲ្យវៀតណាមងាយស្រួលធ្វើអន្តរាគមន៍ពី

ខាងក្រៅដណ្តើមយកកម្ពុជាពីអាមេរិកវិញ ដោយយកលេសថា មកជួយសង្គ្រោះ។ នៅពេលនោះក្នុងការជាក់ស្តែងនោះ ទោះបីចង់ ឬមិនចង់ក៏ដោយ គឺ សេ.អ៊ី.អា និងកុម្មុយនីស្តវៀតណាម ទៅជារួមគ្នាសម្លាប់រដ្ឋអំណាចថ្មីហើយ។ សភាពការណ៍នេះហើយដែលមេៗខ្មែរក្រហមបារម្ភជាងគេបំផុតនោះ”។

[០៩:២៣:៥០]

នៅក្នុងជំពូកដដែលនេះដែរ នៅខាងក្រោមគាត់បានសរសេរ ហើយគាត់បានបញ្ជាក់អំពីទំនាក់ទំនងរវាងបក្ស មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ហើយនិងវៀតណាម ឬក៏អាចនិយាយថា ពីការសង្ស័យរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទៅលើវៀតណាម។ ខ្មែរ ERN 00380498 រហូតដល់ 499, បារាំង ERN 00633909 ដល់ 910, មួយទៀត 00498302។ សូមដកស្រង់ “ប្រសិនបើវៀតណាមបានរំដោះនៅភូមិភាគ-- នៅខាងត្បូង បានរំដោះនោះគឺអាចមានគ្រោះថ្នាក់ធំហើយ។ បន្ទាប់ពីបានរំដោះហើយគឺ យើងត្រូវគ្រប់គ្រងម្តងទៀត គឺយើងមិនមានការអល់អែកនោះទេ។ នេះហើយបានជា ប៉ុល ពត សម្លឹងមើលទៅឃើញថា ការពង្រឹងសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស ធ្វើឲ្យបដិវត្តន៍នៅកម្ពុជាបានលឿនជាងបដិវត្តន៍នៅចិន កូរ៉េ (កូរ៉េខាងជើង) និងវៀតណាម៣០ឆ្នាំ។

នៅខាងក្រោមនោះទៅទៀត ផ្នែកមួយដែលពាក់ព័ន្ធផងដែរ សូមដកស្រង់ “រីឯការរៀបចំសហករណ៍ បើគ្មានការចាត់តាំងសហករណ៍ទេ កម្ពុជានឹងត្រូវទទួលបច្ច័យនៃសភាពការណ៍ទាំងអស់ដែលកើតមាននៅប្រទេសវៀមណាម។ ក្នុងនោះរួមទាំងការគោរពកិច្ចព្រមព្រៀងប៉ារីស ឆ្នាំ១៩៧៣ រវាងវៀតណាម និងអាមេរិកផងដែរ។ ដល់ចុងឆ្នាំ១៩៧២ ដើមឆ្នាំ១៩៧៣ ដោយសារតែមានការដំឡើងថ្នាក់សហករណ៍ ដែលបានចាត់តាំងពីមុនឲ្យទៅជាសហករណ៍កម្រិតខ្ពស់ ហើយបានពួកខ្មែរក្រហមបន្តការតស៊ូដោយឯករាជ្យបាន”។

[០៩:២៦:០៨]

នៅខាងក្រោមនោះបន្តិច នៅក្នុងទំព័របន្ទាប់ គាត់បានសរសេរអំពីភាពចាំបាច់ក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមនោះ គាត់ហាក់ដូចជានិយាយថា យើង ដូចជារួមទាំងគាត់ផងដែរ។ ខ្មែរ ERN 00380499 ដល់ 500, បារាំង 00643910, អង់គ្លេស 00498300។ សូមដកស្រង់ “ដើម្បីឲ្យមានទំនប់ប្រឡាយខ្វែងខ្វាត់ទូទាំងប្រទេសកម្ពុជា និងជនបទ នៅពេលដែលយើងចង់ដោះស្រាយបញ្ហាស្បៀងអាហារឲ្យបានគ្រប់គ្រាន់ យើងចង់ដោះស្រាយបញ្ហា យើងធ្វើឲ្យកសិកម្មទំនើបនោះ បានទៅជាទំនើប បើយើងចង់បោះមូលដ្ឋានដើម្បីកម្ពុជាអាចឈានទៅមានឧស្សាហកម្មជាជំហានៗ បើចង់រត់ឲ្យ

បានលឿនកុំឲ្យវៀតណាមដេញគ្រញិចទាន់ ក៏លោក ប៉ុល ពត សម្លឹងមើលទៅមុខ ហើយនិងវាយប្រហារ ហើយនិងលុបបំបាត់កម្មសិទ្ធិឯកជន ហើយយើងដាក់ខ្លួនយើងនៅក្នុងអង្គភាពនោះដែរ”។

[០៩:២៧:៤១]

នៅក្នុងប្រយោគបន្ទាប់មួយទៀត “ប៉ុន្តែដើម្បីសម្រេចបានគោលបំណងនោះ ដោយថាសារសង្គ្រាមទើបតែរួចផុតពីសង្គ្រាមបំផ្លិចបំផ្លាញ ហើយយើងប្រឈមមុខនឹងការមហន្តរាយអត់ឃ្លានស្លាប់នោះ គឺថាដូច្នេះហើយយើងត្រូវយកជម្នះលើឧបសគ្គទាំងឡាយនោះណា ដោយភាពលំបាកដើម្បីសម្រេចបាន។ ដូច្នេះហើយយើងត្រូវមានការបង្ខំខ្លះនៅក្នុងពេលនេះ។ ការបង្ខំឲ្យមនុស្សធ្វើការ ដោយសារយើងខ្វះអ្វីៗទាំងអស់ គឺយើងនឹងត្រូវធ្វើការចំពោះអ្នកដែលធ្លាប់ធ្វើ ឬក៏អ្នកដែលមិនធ្លាប់ធ្វើ ពីព្រោះពេលវេលាគឺបន្ទាន់ណាស់ យើងត្រូវតែធ្វើ”។

ហើយនៅទីបំផុតលោក លោកស្រីចៅក្រម នៅចុងបញ្ចប់នៃជំពូកទី៥ ក្នុងសៀវភៅនេះមានការសរសេរបញ្ជាក់អំពីចលនាកម្ពុជាប្រជាធិបតេយ្យ ហើយនិងខ្លឹមសារ ឬគំនិតដែល ខៀវ សំផន ចូលរួម។ ខ្មែរ ERN 00380503 ដល់ 04, បារាំង ERN 00649912 ដល់ 913, បាទមួយទៀត ERN 00498305 អង់គ្លេស។

[០៩:២៩:០៧]

“តាមអ្វីដែលយល់ ចលនាកម្ពុជាប្រជាធិបតេយ្យបានគួនាទីសំខាន់ក្នុងរយៈកាលមួយនៃប្រវត្តិសាស្ត្រជាតិទៅហើយ គ្មានអ្នកណាអាចកោសលុបបានទេ។ បើមានអ្នកណាកោស ឬក៏លុប ឬក៏កាឡៃនោះ យើងនាំឲ្យគេឃើញស្នាមកោស ឬស្នាមលុប កែ កាឡៃនោះ ពីព្រោះអ្វី? ពីព្រោះរឿងវាច្បាស់ណាស់ថា សាឡុត ស ឬ ប៉ុល ពត បានបូជាអស់មួយជីវិតរបស់គាត់ ដើម្បីប្រយុទ្ធជាមួយអាមេរិកផងពួកវៀតណាមកុម្មុយនីស្តផង ការពារអធិបតេយ្យរបស់ជាតិ ហើយគេម្នាក់ៗសុទ្ធតែមានស្នៀត មានឧបាយកលដើម្បីអូសទាញ ឬបំភ័ត្តកម្លាំងជាតិ និងកម្លាំងផ្ទៃក្នុងឲ្យទៅជាមួយគេ។ ដូច្នេះការប្រយុទ្ធតឹងតែងណាស់ ចង្អៀតណាស់ចំពោះប្រទេសយើង។ នៅឆ្នាំ១៩៦០ ខ្ញុំក៏ដូចបញ្ញាជនចម្រើនផ្សេងទៀតដែរលុះទៅដល់សំណូមពរដ៏ជ្រាលជ្រៅចង់បានសេដ្ឋកិច្ចឯករាជ្យមួយ សម្រាប់ជាមូលដ្ឋាននៃឯករាជ្យភាពរបស់ប្រទេសខ្ញុំ និងទៅដោយឆន្ទៈមួយដ៏រឹងមាំ ចងចុងបញ្ចប់បុព្វសិទ្ធិ -- ចង់បញ្ចប់បុព្វសិទ្ធិ និងអំពើពុករលួយដែលវានាំឲ្យមនុស្សមួយក្តាប់តូចចេះតែមានឡើងៗ មិនចេះអៀនខ្មាស។ ទន្ទឹមនេះ ខ្ញុំត្រូវព្យាយាមជាមួយអ្វីខ្ញុំមានក្នុងឋានៈជាសមាជិកសភា ហើយគេបាន ខ្ញុំត្រូវបង្ខំចិត្តចេញពីភ្នំពេញដើម្បីសង្គ្រោះ

អាយុជីវិតខ្ញុំ ជ្រកកោនក្រោមកិច្ចការពារនៃចលនាមួយ ដែលតាមរយៈមនុស្សខ្លះ ដែលខ្ញុំធ្លាប់ស្គាល់នៅប៉ារីស កំពុងតែខិតខំតាមទិសដៅមួយប្រហាក់ប្រហែលខ្ញុំដែរ តែតាមវិធីមួយផ្សេងដែលខ្ញុំធ្វើមិនបាន។ ឥឡូវនេះទស្សនៈរបស់គោលជំហររបស់ខ្ញុំនៅតែដដែលឥតមានអ្វីប្រែប្រួលទេ”។

[០៩:៣១:១៤]

នៅទីនេះលោក លោកស្រីចៅក្រម យើងនឹងបន្តទៅផ្នែកបន្ទាប់មួយទៀត ដែលយើងខ្ញុំនឹងដកស្រង់ជម្រាបជូន។ នេះគឺជាសៀវភៅមួយទៀតរបស់លោក ខៀវ សំផន ដែលបានបោះពុម្ពផ្សាយនោះផងដែរ ដែលមានចំណងជើងថា “ប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា ហើយនិងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់”។

ឯកសារ E3/18 ដើម្បីជម្រាបជូនជាសេចក្តីផ្តើម លោក លោកស្រីចៅក្រមជ្រាបហើយ យើងបានដកស្រង់ខ្លឹមសារមួយចំនួនចេញពីសៀវភៅនេះ គឺខ្លឹមសារអំពីតួនាទីរបស់លោក ខៀវ សំផន មុនឆ្នាំ១៩៧០ នោះផងដែរ។ បាទ នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់។

យើងពិនិត្យមើលកថាខណ្ឌមួយចំនួនដែលលោក ខៀវ សំផន បាននិយាយអំពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ហើយជាពិសេសព័ត៌មានដែលគាត់បានចូលរួមនៅក្នុងកិច្ចប្រជុំនៅក្នុងថ្នាក់ដឹកនាំទាំងអស់។ ខ្ញុំសូមចាប់ផ្តើមជាមួយនឹង ERN ជាភាសាខ្មែរ 00103840, បារាំង 00595431 ទៅ 32, អង់គ្លេស 00103752។

[០៩:៣៣:០៥]

នៅក្នុងកិច្ចរបស់ -- កិច្ចប្រជុំរបស់មជ្ឈិមជាបន្តបន្ទាប់ ពិសេសនៅឆ្នាំដំបូងក៏មានលេចឡើងនូវការប្រព្រឹត្តមូលហេតុហួសទៅលើប្រជាជន ហើយមានការណែនាំដើម្បីកែតម្រូវអ្នកទាំងអស់នោះ។ ឧទាហរណ៍និយាយទៅដល់សហករណ៍តូចៗ គឺថាត្រូវធ្វើឲ្យការងារនៅតាមស្រែចម្ការមានការកើនឡើង។ ប្រជាជនជាច្រើនត្រូវបានបញ្ជូនទៅវាលស្រែចម្ការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ។ ពលករដទៃទៀត គឺថាអនុញ្ញាតឲ្យសម្រាកនៅក្នុងភូមិ ដូចជាៗធ្វើបុគ្គី ហើយរៀបចំសម្រាក៣ថ្ងៃក្នុង១ខែ ដោយបន្ថែមរបបហូបរាល់ៗ៣ថ្ងៃនោះ។ ប្រមូលអ្នកបច្ចេកទេស និងបញ្ញាជនមួយចំនួនឲ្យមកភ្នំពេញវិញ ដើម្បីចូលរួមធ្វើការគម្រោងថ្មីមួយចំនួនពិសេស។ ជាពិសេសដើម្បីមកជួយបង្រៀននៅសាលាបច្ចេកទេស។ សារពាក់ព័ន្ធនោះគឺដែលមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលបានយោងទៅតាមសម្តីលោក

ខៀវ សំផន គឺថាមានការចាត់ចែងកិច្ចការនៅតាមជនបទ ស្រែចម្ការ។

សារបន្ទាប់នោះ ខ្ញុំសូមដកស្រង់គឺផ្ទុះបញ្ហាំងអំពីកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលខៀវ សំផន បានចូលរួមដែរនោះ ហើយនៅពេលនោះគេនិយាយថា ប៉ុល ពត គឺជាមេដឹកនាំ ERN ជាភាសាខ្មែរ 00103843 ទៅដល់ 44, បារាំង 00595436 ដល់ 437, អង់គ្លេស 00103754 ទៅ755។ សូមដកស្រង់ "ដែលថាប៉ុល ពត ជាមគ្គុទេសន៍ ក៏ជាប្រវត្តិសាស្ត្រដែលវិភាគ និងសម្រេចមិនចេះខុស។ តាមដែលខ្ញុំបានចូលរួម គណៈអចិន្ត្រៃយ៍បើកទូលាយ ក៏ប៉ុន្តែមិនមានអ្វីកើតឡើងធំដុំនៅក្នុងកិច្ចប្រជុំនោះទេ។ តាមពិតទៅកិច្ចប្រជុំនេះ គឺហាក់បីដូចជាការជួបជុំនៅក្នុងគ្រួសារ គឺភាគច្រើនគឺយកពេលវេលានិយាយ -- ជាញយៗប្រជុំច្រើនតែ វាយកៃ ច្រើនតែនិយាយពីរឿងពេលវេលាយ៉ាងយូរ និយាយគ្នាលេងយ៉ាងយូរ។ ប៉ុន្តែម្នាក់ៗជឿជាក់ឥតព្រំដែនលើ ប៉ុល ពត។ នៅពេលមួយ នៅពេលក្រោយមកគឺនៅពេលគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមត្រូវបានចាប់ខ្លួន គឺមេដឹកនាំមានការទុកចិត្តទៅលើ ប៉ុល ពត។ គណៈអចិន្ត្រៃយ៍គឺថាយល់ឃើញថា ការបាត់ខ្លួនរបស់មេដឹកនាំនោះ គឺជាករណីមួយដាច់ដោយឡែក"។

[០៩:៣៦:៤០]

សារបន្ទាប់ដែលខ្ញុំសូមដកស្រង់នោះ គឺ ខៀវ សំផន និយាយអំពីមូលហេតុដែលនាំឲ្យគាត់ចូលរួម ឬក៏ទទួលតួនាទីជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ឬក៏ថាគាត់ជាប្រមុខរដ្ឋ។ ERN ជាភាសាខ្មែរ 00103846 ទៅដល់ 47, បារាំង 00595443, អង់គ្លេស 00103757។ នៅក្នុងសេចក្តីផ្តើមនេះ គឺនិយាយអំពីការរំដោះដោយឯករាជ្យនៅចុងទសវត្សរ៍នៃការគ្រប់គ្រងអំណាចរបស់សម្តេចនរោត្តម សីហនុ។ សូមដកស្រង់ "អ្នកដឹកនាំខ្មែរ បានទទួលយកការដឹកនាំរបស់ប្រមុខរដ្ឋនៅឆ្នាំ១៩៧៦ ហើយមុខងាររបស់សម្តេច គឺថាត្រូវបានប្រគល់មកឲ្យខ្ញុំ ជាជាងការអៀនខ្មាសរបស់ខ្ញុំនោះ គឺដោយមនសិការដាច់ខាតរបស់ខ្ញុំ គឺខ្ញុំបានបដិសេធមិនទទួលយកតួនាទីនេះទេ។ ប្រហែលជានៅក្នុងកិច្ចការស្នេហាជាតិរបស់ខ្ញុំ អាចនឹងខ្ញុំបរាជ័យ ហើយយើងឃើញថាតើមេដឹកនាំវៀតណាមនោះនៅក្នុង៧០ និងឆ្នាំ៧៥ ដែលខ្ញុំមានការយល់ឃើញថា ដូចអ្នកដឹកនាំបក្សកម្ពុជាដែរ ហើយខ្ញុំមិនចង់ឲ្យកម្លាំងដែលស្ថិតនៅកម្លាំងស្នូលរបស់ជាតិនោះចុះខ្សោយទេ"។

ហើយសារចុងក្រោយដែលខ្ញុំសូមដកស្រង់នៅថ្ងៃនេះ គឺសង្ខេបទេ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួននៅព្រះវិហារដែល ខៀវ សំផន គាត់បានអះអាងថា នៅពេលដែលគាត់ឆ្លើយ -- គាត់បានដឹងនៅពេលគាត់ឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេត ERN មានដូចតទៅនេះ ខ្មែរ 00103891, បារាំង

00595513, អង់គ្លេស 00103793 "នៅរវាងពាក់កណ្ដាលឆ្នាំ៧៨ ខ្ញុំបានឮដោយចៃដន្យអំពីករណីមួយនៃការចាប់ចង និងអំពើឃោរឃៅនៅក្នុងខេត្តព្រះវិហារ។ គឺប្រពន្ធខ្ញុំបាននិយាយប្រាប់ខ្ញុំទាំងទឹកភ្នែកអំពីបងប្អូនបង្កើត និងសាច់ញាតិរបស់គាត់ត្រូវបានដាក់ខ្នោះដៃ ខ្នោះជើងអស់រយៈជាង១ឆ្នាំ។ ប៉ុន្តែដោយការដោះលែងជនរងគ្រោះ និងការចាប់ខ្លួនលេខាបក្សភូមិភាគ នោះក៏នាំឲ្យខ្ញុំគិតថា រឿងនេះគឺជាអំពើឃោរឃៅរបស់បុគ្គលតែប៉ុណ្ណោះ។

[០៩:៤០:២៦]

នៅសារចុងបញ្ចប់ខ្ញុំសូមលើកឡើងនូវសេចក្ដីថ្លែងការណ៍របស់អ្នកដទៃទៀត ដូចដែលខ្ញុំបានជម្រាបជូនអង្គជំនុំជម្រះពីខាងដើមហើយ គឺនឹងនិយាយអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ ជាពិសេសនៅពេលមានការបាត់ខ្លួន សឿ វ៉ាស៊ី ហៅ ឌឿន ដែលជាអតីតប្រធានមន្ទីរ៨៧០នេះ។ ឯកសារ E3/110 -- (សូមកែប្រែ) ឯកសារ E3/190 គឺជារបាយការណ៍ ឬសេចក្ដីសង្ខេបរបាយ-ការណ៍នៃការពិភាក្សារវាង អៀង សារី ដែលសម្ភាសដោយ អៀង សារី នៅថ្ងៃទី៤ មករា ១៩៩៩។ ខ្ញុំសូមលើកឡើង ERN គឺ 00172248, បារាំង 00607965, អង់គ្លេស 00081572 បាទ យើងខ្ញុំសូមដកស្រង់អំពីការសម្ភាស -- ពិភាក្សារបស់គាត់ជាមួយនឹង អៀង សារី "ខ្ញុំបានសង្កត់ -- ខ្ញុំប្រៀបធៀបអំពីតួនាទីរបស់ ខៀវ សំផន ជាមួយនឹងតួនាទីរបស់គាត់។ គាត់បានបញ្ជាក់ថា ការដែល ខៀវ សំផន ឡើងទៅចូលគណៈ -- ចូលទៅក្នុងគណៈអចិន្ត្រៃយ៍នៅឆ្នាំ១៩៧៦ រហូតទៅដល់ក្លាយទៅជាប្រធានមន្ទីរ ៨៧០ គាត់បានអះអាងថា នៅក្នុងសមត្ថភាពចុងក្រោយរបស់គាត់នោះ ខៀវ សំផន អាចបានឃើញឯកសារជាច្រើនជាងគាត់ឃើញ ប៉ុន្តែមិនពាក់ព័ន្ធអ្វីដែលទាក់ទងទៅនឹងឯកសារដែលត្រូវកាប់សម្លាប់ ឬក៏ធ្វើទារុណកម្មនោះទេ។

[០៩:៤២:៣២]

គាត់បាននិយាយម្ដងហើយម្ដងទៀតថា ខៀវ សំផន ក៏ដូចជាគាត់បន្តជឿជាក់ថា បក្ស -- កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលចាប់ខ្លួននោះ សូមដកស្រង់ "គឺត្រូវយកទៅរៀនសូត្រ គឺមិនយកទៅសម្លាប់ចោលនោះទេ"។ ការអះអាងអំពីការ ខៀវ សំផន ឡើងកាន់មុខតំណែងជាប្រធានមន្ទីរ៨៧០ គឺនៅក្នុងឯកសារ E190.1.72 ដែលយើងខ្ញុំសូមបង្ហាញជូនអង្គជំនុំជម្រះនៅក្នុងថ្ងៃនេះ គឺជាឯកសារមួយដែលនឹងត្រូវសាកសួរទៅលើសាក្សីជំនាញ។ ចុងក្រោយបំផុត សូមលើកឡើងសេចក្ដីថ្លែងការណ៍របស់អ្នកដទៃទៀតទាក់ទងទៅនឹងតួនាទី ខៀវ សំផន នៅក្នុងភាពជាអ្នកដឹកនាំ គឺឯកសារ E3/464 ជា

កំណត់ហេតុលាយលក្ខណ៍អក្សរនៃការសម្ភាសសាក្សីឈ្មោះ តាសុត, ឈ្មោះ ថា សុត ដែលថា ថា សុត នេះគឺគាត់បានស្លាប់បាត់ទៅហើយ យោងទៅតាមព័ត៌មាននៅក្នុងសំណុំរឿង គឺគាត់បាត់បង់ជីវិតហើយ អង្គជំនុំជម្រះប្រហែលនៅចាំហើយ គឺថាយើងបានចង់សួរឈ្មោះ ថា សៀក ដែលជាប្រពន្ធរបស់ ថា សុត នេះ។ បាទ ស សៀក ដែលជាប្រពន្ធរបស់ ថា សុត ដែលត្រូវបានសម្ភាស ថា សុត នេះគឺថា គាត់គឺជានារីកងវរសេនាធំដែលត្រូវគ្រប់គ្រងទាហាន៥០០នាក់ នៅភូមិភាគឧត្តរនៅក្នុងសមត្ថភាពរបស់គាត់នៅពេលវាយប្រហារចូលរំដោះទីក្រុងភ្នំពេញ។ ចំពោះគោលបំណងនៅពេលបច្ចុប្បន្ននេះ ខ្ញុំសូមដកស្រង់ សារដែលគាត់បាននិយាយអំពីតួនាទីរបស់ ឈឹម សំអោក ហៅ ប៉ង់ ហើយនិងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា យើងអាចរកឃើញនៅ ERN ភាសាខ្មែរ 00204741, បារាំង 00503948, អង់គ្លេស 002246106 (ស៊ីក) ដែលបានលើកឡើងដូចខាងក្រោមនេះ "ប៉ង់ គ្រប់គ្រងគ្រប់មន្ទីរ"ក"ទាំងអស់ ដូចជា ក-១, ក-២, ក-៣, ក-៤, ក-៧ និង ក-១២។ ប៉ង់ គឺថាមុននឹងគាត់ធ្វើសេចក្តីសម្រេចណាមួយ គាត់ត្រូវទៅជួប ប៉ុល ពត សិន។ ក្រោយមក ប៉ង់ បានចែកចាយនូវបទបញ្ជានេះទៅមន្ទីរដទៃទៀត។ ប៉ង់ ទទួលបទបញ្ជាពីអ៊ំៗទាំងអស់ ដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា ហើយយកទៅតាមជំនាញរបស់គាត់នេះ គឺទទួលនូវសេចក្តីណែនាំអំពីភារកិច្ចទាំងអស់នេះ។ ប៉ង់ ចាត់ចែងគ្រប់មន្ទីរ"ក"ទាំងអស់។ ប៉ង់ ធ្លាប់ជួបជាមួយ ខៀវ សំផន នៅក-៣ ហើយខៀវ សំផន ក៏ធ្លាប់ជួបប៉ង់ នៅក-៧ ដែរ។ ខ្ញុំបានឃើញ។ ប៉ង់ គឺជាប្រធានមន្ទីរ៨៧០ មុននឹងគាត់ស្លាប់នៅក្នុងឆ្នាំ១៩៧៦"។

[០៩:៤៦:២០]

សារពាក់ព័ន្ធមួយទៀតគឺសំណួរនៃកិច្ចសម្ភាសន៍ទី២ ដែលជាកិច្ចសម្ភាសន៍ចុងក្រោយ សូមដកស្រង់ "ខ្ញុំធ្លាប់ចែកចាយលិខិតទៅតាមបណ្តាខេត្តផ្សេងៗ ក៏ប៉ុន្តែខ្ញុំមិនដឹងថា មានអ្វីសរសេរនៅក្នុងលិខិតនេះ ដោយសារថាលិខិតទាំងនោះគឺត្រូវមានបិទស្រោម គឺត្រូវចែកចាយទៅឲ្យអ៊ំ ប៉ុល ពត, នួន ជា, អ៊ំ ខៀវ សំផន និងអ៊ំ អៀង សារី។ លិខិតភាគច្រើនគឺចេញមកពីអ៊ំ នួន ជា និង ប៉ុល ពត ដែលត្រូវផ្សព្វផ្សាយទៅដល់មេភូមិភាគ"។ ហើយខាងក្រោមមកទៀតនោះ គឺជាសារ សូមដកស្រង់ "ខ្ញុំធ្លាប់ចែកលិខិតពី ប៉ុល ពត, ពីនួន ជា, អៀង សារី, ខៀវ សំផន ទៅឲ្យប្រធានតំបន់ព្រះវិហារ, ប្រធានតំបន់សៀមរាប តាសុក, និងប្រធានភូមិភាគនៅព្រៃវែង សោ ភឹម, ប្រធានតំបន់ស្ទឹងត្រែងឈ្មោះ លី និង ធំ*(ឮមិនច្បាស់)* ប្រធានតំបន់ពោធិ៍សាត់, ប្រធានតំបន់បាត់ដំបងគឺ ញឹម, ប្រធានតំបន់កំពត តាម៉ុក,

ប្រធានតំបន់កំពង់ស្ពឺ តាស៊ី។ ខ្ញុំដឹងថា លិខិតមកពីអ៊ំៗគឺផ្ញើទៅភូមិ តំបន់ ប៉ុន្តែខ្ញុំអត់បានចែកជូននោះទេ ខ្ញុំមិនបានបញ្ជូនទៅទេ”។

[០៩:៤៨:១៤]

ឯកសារទី២ ជាឯកសារចុងក្រោយ ដែលយើងខ្ញុំសូមបង្ហាញជូនអង្គជំនុំជម្រះនៅថ្ងៃនេះគឺ E3/3512 វាជាព្រឹត្តិប័ត្រដែលសរសេរឡើងដោយ ប៉ែន យៀវនិន ដែលពិភាក្សាអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ជាការពិតគឺជាការឆ្លើយតបទៅនឹងសៀវភៅទី២ ដែលខ្ញុំទើបតែបានដកស្រង់ខាងដើមនេះ។ យើងខ្ញុំសូមដកស្រង់នៅត្រង់ERN ជាភាសាខ្មែរ 00755594, បាទ សូមកែប្រែ នេះគឺជាERN ជាភាសាបារាំង, ឯខ្មែរវិញគឺ 00758170, អង់គ្លេស 0080475 “ដូចប្រជាជនកម្ពុជាឯទៀតដែរ សម្តេច សីហនុ បានឃើញអ្វីៗគ្រប់បែបយ៉ាងទាំងអស់។ ប៉ុន្តែផ្ទុយទៅវិញ សំផន បានយល់ដឹងតិចតួចណាស់ ក្រោយពីបានរត់ចូលព្រៃរយៈពេល៣២ឆ្នាំបន្ទាប់មក គាត់បានលេចរូបរាងឡើងដោយមិនមានព័ត៌មានអ្វី ហើយគាត់ហាក់បីដូចជាមិនដឹងថាមានឯកសារផ្ទៃក្នុងរបស់គាត់ចំនួនប៉ុន្មានដែលមានសាធារណៈនោះទេ។

ពីរកថាខណ្ឌ កថាខណ្ឌពីរមកខាងក្រោមទៀតនេះ គឺគាត់បាននិយាយដូចតទៅនេះ សូមដកស្រង់ “សំផន បាន-- គឺថាប្រជាជនបានជឿជាក់គាត់” បាទសូមអានម្តងទៀត សូមដកស្រង់ “សំផន បានគិតឃើញថាអ្នកស្នេហាជាតិ គឺគាត់ទទួលយកមុខងារជាប្រធានគណៈប្រធានរដ្ឋ ក្នុងក្រោយពីឆ្នាំ១៩៧៥ ជ័យជម្នះនេះដោយសារវាជាកាតព្វកិច្ចរបស់គាត់”។ គាត់ថាមានការភ្ញាក់ផ្អើលដែលគាត់មិនបានដឹង ស្ទើរតែមិនដឹងទាល់តែសោះ នូវការអំពីប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៧៦ ដល់៧៥ (ស៊ីក) គាត់អះអាងថា សូមដកស្រង់ “មេដឹកនាំខ្មែរក្រហមជាអ្នកប្រព្រឹត្ត-- ជាអ្នកទទួលខុសត្រូវមិនមែនគាត់នោះទេ ហើយមិនបានផ្តល់ព័ត៌មានទាំងអស់នេះមកឲ្យគាត់ទេ។ ឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យនោះ គឺគាត់មានការភ្ញាក់ផ្អើលរន្ធត់ណាស់”។ ឥឡូវនេះ សំផន គិតថាគាត់គឺជាអ្នករស់រានមានជីវិតម្នាក់ដូចជាអ្នកនៅក្នុងទីបញ្ជាការកម្ពុជាប្រជាធិបតេយ្យ គឺគាត់មានការអាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំងដោយបក្សកុម្មុយនីស្តកម្ពុជាបានបង្ខំប្រជាជនឲ្យចេញពីទីក្រុង ក្រោយពីការដួលរលំនៅក្នុងឆ្នាំ១៩៧៥។ ដូចជា ហ៊ូ យន់ បានប្រឆាំង សំផន បានហៅការជម្លៀសប្រជាជនដោយបង្ខំថា “ខ្ញុំមិនបានគិតដល់ទាល់តែសោះ”។

[០៩:៥១:៤៨]

ទន្ទឹមគ្នានេះដែរ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ប្រជាជនឲ្យរស់នៅតាមសហករណ៍ដោយបង្ខំ។ សូមដកស្រង់ គាត់អះអាងថា "ដោយដឹងអំពីព័ត៌មាននេះ បន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៥ រហូតមកដល់ពេលនេះ គាត់គឺ-- រហូតមកទាល់ពេលនេះ គាត់អាចជាប្រជាជនតែមួយគត់នៅក្នុងប្រទេសដែលមិនបានដឹងឮអំពីលក្ខណៈសហករណ៍នេះ។ ភស្តុតាងឯកសារបង្ហាញផ្ទុយពីការមិនដឹងមិនឮដែលថាគោលនយោបាយថ្នាក់លើដែល សំផន អះអាងនោះ។ គាត់បានទទួលសារភាពថា គាត់គឺជាសមាជិកពេញសិទ្ធិគណៈមជ្ឈិមបក្សកម្មុយនីស្តកម្ពុជាពីឆ្នាំ៧៦ ប៉ុន្តែមិនមែនជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍ដ៏មានអំណាចនោះទេ។ គាត់និយាយថាគាត់គ្រាន់តែចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ជាទ្រង់ទ្រាយធំ ប៉ុន្តែទោះបីជាយ៉ាងណាកំណត់ហេតុអង្គប្រជុំធ្វើឡើងក្នុងរយៈពេលពីឆ្នាំ៧៥ ដល់៧៦ មានបានកត់ត្រាវត្តមាន ខៀវ សំផន ចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចំនួន១២ដង ក្នុងចំណោម១៤ដង។ សូមដកស្រង់ "ការប្រជុំដោយមានការអញ្ជើញចូលរួមតិចតួចមិនមែនទ្រង់ទ្រាយធំ" សូមបិទការដកស្រង់។ សំផន ពិតជាចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់ខ្ពស់ដោយសម្ងាត់នានារបស់ ប.ក.ក។ ក្រោយពីពេលដែលគាត់បានទទួលដឹងឮពីការប្រជាជនចេញពីទីក្រុង និងការដាក់ឲ្យប្រជាជនរស់នៅជាលក្ខណៈសមូហភាព នៅពេលនោះហើយឯកសាររបស់មជ្ឈិមបក្សមិនត្រឹមតែបង្ហាញពីតួនាទីសំខាន់របស់ ខៀវ សំផន តែប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងថ្ងៃទី០៩ តុលា ឆ្នាំ៧៥ គាត់បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលនៅក្នុងនោះ គេបានតែងតាំងខ្លួនគាត់ផ្ទាល់ថាជារដ្ឋាភិបាលសម្ងាត់របស់កម្ពុជា។

[០៩:៥៣:៣៣]

កំណត់ហេតុបានកត់ត្រាវត្ត មានលោក ខៀវ សំផន លំដាប់ទី៤ នៅក្នុងឋានានុក្រមរបស់ខុទ្ទកាល័យ គឺបន្ទាប់ពី ប៉ុល ពត, នួន ជា និង ខៀវ សំផន។ នៅក្នុងកិច្ចប្រជុំសម្ងាត់នេះ ប៉ុល ពត បានកំណត់ទិសដៅជាទូទៅ ទៅលើ ចាន់ ចក្រី។ សូមដកស្រង់ "យើងត្រូវចាប់អារម្មណ៍ទៅលើអ្វីដែលវានិយាយ ដើម្បីឲ្យបានដឹងថា តើវាជាជនក្បត់ ដើម្បីនឹងរារាំងកុំឲ្យវាធ្វើអ្វីនៅពេលអនាគត" ហើយបន្ទាប់មក ប៉ុល ពត បន្ថែមថា "យើងត្រូវរក្សាការសម្ងាត់ឲ្យបានដាច់ខាត យើងត្រូវឃ្លាំមើលគ្រប់សកម្មភាពរបស់ពួកវា"។ បិទការដកស្រង់។

ហើយសារបន្ទាប់មកទៀត នៅក្នុងអត្ថបទដែលខ្ញុំសូមអានជូនអង្គជំនុំជម្រះ ERN ជាភាសាខ្មែរ 00758173 ដល់ 174, បារាំង 00755596, អង់គ្លេស 00080476។ សូមដកស្រង់ "សំផន មិនសូវជាស្ងប់ស្ងៀមប៉ុន្មាននោះទេ ចំពោះជោគវាសនារបស់ ហ៊ូ នឹម ជាសមាជិកសភាឆ្វេងនិយមមួយរូបដែល

មិនដូច សំផន ឡើយ បានតវ៉ាជំទាស់ទៅនឹងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យហើយត្រូវបានចាប់ខ្លួនក្នុងខែមេសា ៧៥។

[០៩:៥៥:០១]

អ្នកធ្វើទារុណកម្មទៅលើ ហ៊ូ នឹម បានរាយការណ៍ថា "យើងបានវាយគាត់ពីបួនទៅប្រាំដងដើម្បីបំបាក់ជំហររបស់គេ ក្នុងពេលនាំយកគាត់ទៅជ្រមុជទឹក" បញ្ចប់ការដកស្រង់។ សំផន ប្រហែលជាមិនបានអានរបាយការណ៍នោះទេ ប៉ុន្តែនៅពេលដែលដឹងថា ហ៊ូ នឹម ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ គាត់បានថ្លែងតាមវិទ្យុនៅថ្ងៃបន្ទាប់ថា "យើងត្រូវតែបោសសម្អាតខ្មាំងរបស់យើងឲ្យអស់ ឲ្យបានហ្មត់ចត់ ព្រមទាំងបង្រ្កាបរាល់ខ្សែរយៈរបស់ខ្មាំងទាំងអស់"។ នៅថ្ងៃ០៦ កក្កដា កងកម្លាំងសន្តិសុខប.ក.ក បានសម្លាប់ ហ៊ូ នឹម និងអ្នកផ្សេងទៀតដែលមានចំនួន១២៦នាក់។ នាពេលនេះក្នុងនាមជាជនរងគ្រោះ សំផន បានអះអាងថា "ហ៊ូ នឹម គឺជាមិត្តភក្តិរបស់ខ្ញុំ និងគ្រញែងខ្លួនចំពោះការឈឺចាប់នៅក្នុងអារម្មណ៍ និងនៅក្នុងខ្លួនរបស់គាត់នៅពេលនោះ ថាជាសុបិនដ៏អាក្រក់"។ បិទការដកស្រង់។ ការសម្តែងនេះមិនអាចបញ្ចូលឲ្យយើងជឿជាក់ឡើយទៅលើការអះអាងរបស់ សំផន មិនបានដឹងឮអ្វីរឿងនៅពេលនោះ គាត់មិនបានដឹងឮ សូម្បីតែកាប់សម្លាប់រង្គាលនូវឧក្រិដ្ឋកម្មទាំងនោះ។ បញ្ចប់ការដកស្រង់។

[០៩:៥៦:១៥]

លោកប្រធានឯកសារចុងក្រោយ ដែលយើងខ្ញុំចង់បង្ហាញជូនអង្គជំនុំជម្រះនៅថ្ងៃនេះគឺ សេចក្តីដកស្រង់ចេញពីខ្សែវីដេអូ ភាពយន្តឯកសារដែលយើងបានឃើញផ្នែកខ្លះនៃខ្សែភាពយន្តនេះពីមុនរួចមកហើយ ដែលមានចំណងជើងថា "ប៉ុល ពត និង ខៀវ សំផន ចោទប្រកាន់អំពីប្រល័យពូជសាសន៍" គឺ E3/209/2.3R។ ជាកំណត់ហេតុលើកទី៦ និងជាសេចក្តីថ្លែងការណ៍លើកទី២២ ដែល ខៀវ សំផន បានពិភាក្សានូវឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ពីការចោទប្រកាន់ទៅលើការទទួលខុសត្រូវរបស់គាត់ និងតួនាទីដែលបានបំពេញទៅដោយ ប៉ុល ពត ហើយចុងក្រោយគឺតួនាទីរបស់គុក ស-២១ មន្ទីរសន្តិសុខ ស-២១ នោះ"។ ហើយយើងខ្ញុំសូមឲ្យខាងផ្នែកអេ.វី ចាក់បង្ហាញនូវខ្សែវីដេអូ ដែលយើងអាចឃើញនៅត្រង់ថា J2 គឺខ្សែវីដេអូមានចំណងជើងថា J2 ដែលមានរយៈពេល៦នាទី និង១៨វិនាទី។

បាទ លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតឲ្យខាងផ្នែក អេ.វី ដើម្បីចាក់បង្ហាញនូវខ្សែវីដេអូ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! អ្នកបច្ចេកទេសខាងសោតទស្សន៍ចាក់ផ្សាយនូវវីដេអូលើអេក្រង់ទូរទស្សន៍ តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[០៩:៥៨:១០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អ្នកសម្ភាស៖ ក្នុងឋានៈជាប្រមុខរដ្ឋ តើលោកដឹងថាមានការសម្លាប់រង្គាលយ៉ាងសម្បើមនៅពេលណា? លោក ខៀវ សំផន៖ គឺនៅពេលខ្ញុំត្រឡប់ទៅប៉ៃលិនវិញ នៅចុងឆ្នាំ១៩៩៨។ ពេលនោះខ្ញុំឮគេនិយាយអំពីការកាប់សម្លាប់រង្គាលរួចទៅហើយ ក៏ប៉ុន្តែទាល់តែខ្ញុំមើលខ្សែភាពយន្តរបស់ រិទ្ធី ប៉ាន់ ទើបខ្ញុំដឹងថាមាន ស-២១។ អ្នកសម្ភាស៖ តើលោកមានប្រតិកម្មភ្លាមៗយ៉ាងម៉េចដែរ នៅពេលដែលលោកដឹងអំពីការឈឺចាប់នេះ? លោក ខៀវ សំផន៖ ប្រតិកម្មភ្លាមៗរបស់ខ្ញុំគឺថាខ្ញុំភ្ញាក់ផ្អើល។ អ្នកសម្ភាស៖ ពេលដែលលោកដឹងថា មានការសម្លាប់រង្គាលកុមារ មនុស្សចាស់ តើលោកមានការភ័យរន្ធត់ដែរឬទេ? ខៀវ សំផន៖ ខ្ញុំមានការភ្ញាក់ផ្អើល ហេតុអ្វីបានជាមានការសម្លាប់ក្រោយទទួលជ័យជម្នះបែបនេះ។ អ្នកសម្ភាស៖ ប៉ុន្តែការសម្លាប់កុមារបែបនេះ លោកមិនមានការរន្ធត់ទេឬ? លោក ខៀវ សំផន តើអ្នកណាជាអ្នកសម្លាប់! នេះជាសំណួរដែលយើងចង់ដឹង ជាចុងក្រោយខ្ញុំមិនអាចស្រមៃថា ប៉ុល ពត ជាអ្នកសម្លាប់កុមារនោះទេ។ តើលោកឃើញ ប៉ុល ពត សម្លាប់កុមារនៅឯណា? តើលោកឃើញ ប៉ុល ពត ធ្វើទារុណកម្មកុមារនៅឯណា? នៅកន្លែងណា? បង្ហាញខ្ញុំមើល៍!*

[០៩:៥៩:៤៩]

*អ្នកសម្ភាស៖ តាមពិតទៅ ឃាតកជាច្រើនជាកុមារផ្ទាល់តែម្តង ហើយជាកុមារទាំងអស់នេះត្រូវបានជ្រើសរើស និងបង្វឹកដោយពួកខ្មែរក្រហម។ តើលោកគិតយ៉ាងណាចំពោះកុមារទាំងនេះ? លោក ខៀវ សំផន៖ សូមលោកជ្រាប ខ្ញុំបាននិយាយប្រាប់លោកអំពីកុមារក្រីក្រកម្ពុជានៅទសវត្សរ៍ឆ្នាំ៧០ ដែលស្នើសុំចុះឈ្មោះចូលធ្វើជាទាហាន ហើយដោយមានការជំរុញអំពីឪពុកម្តាយរបស់ពួកគេ។ ហើយពួកគេបានចូលរួមក្នុងការរំដោះប្រទេសជាតិ។ ពួកគេយល់ថាត្រូវការយុត្តិធម៌សង្គម ដែលពួកគេបាត់បង់តាំងពីសម័យកាលក្រោយអង្គរមកម្ល៉េះ។ អ្នកសម្ភាស៖ កុមារក្មេងជាងគេបំផុតនៅស-២១ មានអាយុ១០ឆ្នាំ។ តើកុមារនេះពិតជាគិតបែបនេះមែនទេ? លោក ខៀវ សំផន៖ ចំពោះករណីនេះ ខ្ញុំមិនដឹងមូលហេតុនោះទេ ក៏ប៉ុន្តែមានតែក្មេងៗតិចតួចប៉ុណ្ណោះ។ នេះមិនមែនជាមូលហេតុដែលត្រូវលុបបំបាត់*

*ឬក៏បដិសេធចោលនូវសម័យកាលទាំងមូលនៃប្រតិសាស្ត្រនោះទេ។ អ្នកសម្ភាសៈ តើហេតុអ្វីបានជាកុមារអាយុ១០ឆ្នាំចង់សម្លាប់កុមារដទៃទៀតអ៊ីចឹង? លោក ខៀវ សំផនៈ ខ្ញុំមិនដឹងមូលហេតុនោះទេ យើងត្រូវរកមូលហេតុ យើងត្រូវរក ត្រូវជីកកកាយ។ ហេតុនេះហើយបានជាខ្ញុំនិយាយថាត្រូវធ្វើការស្រាវជ្រាវជាច្រើនទៀត។ លោកត្រូវយល់ថា បើគ្មាន ប៉ុល ពត បើគ្មានខ្មែរក្រហមនោះទេ ចាប់តាំងពីសម័យក្រោយរដ្ឋប្រហារឆ្នាំ៧០នោះ កម្ពុជាធ្លាក់ក្នុងកណ្តាប់ដៃពួកកុម្មុយនីស្តវៀតណាមបាត់ទៅហើយ។ សូមកុំភ្លេចរឿងនេះឲ្យសោះ។*

[១០:០២:២១]

*ចំពោះយើងជាជនកម្ពុជា តើធ្លាក់ក្នុងកណ្តាប់ដៃវៀតណាមមានន័យថាយ៉ាងម៉េច? តើមានន័យថាយ៉ាងម៉េច? មានន័យថាមិនចាំបាច់ត្រូវការពេលច្រើនទេ ដើម្បីឲ្យកម្ពុជាបច្ចុប្បន្នក្លាយជាកម្ពុជាដូចកម្ពុជាក្រោមនោះ។ តើលោកដឹងថាប្រជាជនប៉ុន្មានលាននាក់នៅកម្ពុជាក្រោមរស់នៅយ៉ាងម៉េចនាពេលបច្ចុប្បន្ននេះ? ខ្ញុំសូមប្រាប់លោកថា នេះគឺជាស-២១ ដ៏សម្បើមហើយ កម្ពុជាក្រោមនោះ តើមែនទេ? ប្រៀបធៀបជាមួយនឹងស-២១ ដ៏តូចនៅកម្ពុជានេះ តើលោកចង់បំភ្លេចស-២១ ដ៏ធំសម្បើមនៅកម្ពុជាក្រោមមែនទេ? នេះជាល្បិចកលដ៏ឈ្លាសវៃនៅក្នុងការបំភ័ន្តភ្នែកមតិពិភពលោក។ ការបង្ហាញកម្ពុជាបង្ហាញ ប៉ុល ពត ថា ប៉ុល ពត ជាបិសាចដើម្បីបំភ្លេចស-២១ នៅកម្ពុជាក្រោម។ ចោទ ប៉ុល ពត ថាជាជនផ្តាច់ការប្រព្រឹត្តអំពើប្រល័យសាសន៍នោះគឺមិនត្រឹមត្រូវទេ។ មេដឹកនាំចលនាដ៏ធំបែបនេះមិនអាចធ្វើអ៊ីចឹងបានទេ បើគាត់ធ្វើអ៊ីចឹងមែននោះ គាត់មិនអាចបង្កើតចលនាតស៊ូបែបនេះបានទេ។ ខ្ញុំនឹងស្រែកបែបនេះនៅមុខតុលាការ។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:០៤:៣៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះជាសេចក្តីបញ្ចប់បទឧទ្ទេសនាមបង្ហាញឯកសាររបស់ខ្ញុំ ដែលទាក់ទងទៅនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ សូមអរគុណ ដែលតុលាការបានផ្តល់ឱកាសឲ្យខ្ញុំតំណាងសហព្រះរាជអាជ្ញានឹងធ្វើបទឧទ្ទេសនាមនេះ។ សូមអរគុណលោក លោកស្រីចៅក្រមបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ថា តើមានអ្វីត្រូវធ្វើអត្ថាធិប្បាយបន្ថែមលើបណ្ដាឯកសារភស្តុតាងគន្លឹះនានា ដែលតំណាងសហព្រះរាជអាជ្ញាដាក់បង្ហាញកន្លងមកនេះទេ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ អៀង សារី និង ខៀវ សំផន។ ប្រសិនបើមានសូមអញ្ជើញ!

[១០:០៥:២៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ ខ្ញុំសូមរំឭកជាថ្មីម្ដងទៀត។ យើងចង់ធ្វើការបង្ហាញឯកសារក្រោយពេលសវនាការមានការពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ។ យោងទៅតាមយុត្តិសាស្ត្រអន្តរជាតិដែលយើងគោរពតាមផងដែរនោះ គឺថាយើងអាច -- យើងមិនអាចដាក់ឯកសារដែលថាមេធាវីការពារក្ដី សូមអភ័យទោសដោយសារឃ្លា ខ្ញុំដូចស្មុគស្មាញ ខ្ញុំសូមនិយាយម្ដងទៀត។

យើងមិនអាចដាក់ឯកសារដោយមិនឲ្យមេធាវីជនជាប់ចោទ ឬក៏មិនឲ្យជនជាប់ចោទប្រឈមមុខនឹងអ្នកសរសេរឯកសារទាំងអស់នោះទេ។ អង្គជំនុំជម្រះប្រសិនបើចង់ស្ដាប់សក្ខីកម្មសាក្សី ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទនោះ ក្រោយមកយើងនឹងដាក់ឯកសារ។ នៅក្នុងបញ្ជីបឋមរបស់យើង យើងបានដាក់ឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលអាចមកធ្វើសក្ខីកម្មអំពីតួនាទីរបស់ជនជាប់ចោទ។ ប្រសិនបើអង្គជំនុំជម្រះចង់ដកចេញដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនពីក្នុងបញ្ជីទាំងអស់នោះ ដែលគាត់អាចនឹងប្រឈមមុខជាមួយនឹងជនជាប់ចោទនោះ។ យោងទៅតាមយុត្តិសាស្ត្រអន្តរជាតិនោះគឺថា យើងនឹងដាក់ឯកសារទាំងអស់នោះគឺថានៅពេលក្រោយ នៅពេលដែលស្ដាប់សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីអំពីតួនាទីរបស់ជនជាប់ចោទរួចហើយនោះ យើងនឹងដាក់ឯកសារក្រោយពេលនោះ គឺនៅក្រោយពេលដែលអង្គជំនុំជម្រះបើកសវនាការស្ដាប់សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីអំពីតួនាទីរបស់ជនជាប់ចោទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ប៉ុន្តែអាចស្ដាប់មិនយល់។ អង្គជំនុំជម្រះបានផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា តើមានអ្វីចង់ធ្វើអត្ថាធិប្បាយបន្ថែមទៅលើបណ្ដាឯកសារទាំងឡាយដែលតំណាងសហព្រះរាជអាជ្ញាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងតួនាទីរបស់

ជនជាប់ចោទពីររូប លោក អៀង សារី និង ខៀវ សំផន ដែរឬទេ? នេះជាការផ្តល់ឱកាសទៅជូនក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ យើងបានដឹងច្បាស់អំពីដើមបណ្តឹងរដ្ឋប្បវេណីធ្វើមិនទាន់រៀបចំមិនទាន់ ហើយទុកពេលវេលាសមស្របណាមួយសម្រាប់រៀបចំនូវឯកសារពាក់ព័ន្ធនឹងតួនាទីរបស់ជនចាប់ចោទដោយឡែកមួយផ្សេងទៀតដែលពេលនេះ អង្គជំនុំជម្រះមិនលើកឡើងមកនិយាយដដែលនោះទេ។

[១០:០៨:៣៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធានចំពោះការបញ្ជាក់នេះ។ គឺថាយើងខ្ញុំមិនមានយោបល់អ្វីទៅលើការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញានោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការឡើងធ្វើអត្ថាធិប្បាយ ឬក៏និងជំទាស់ទៅនឹងបណ្តាឯកសារភស្តុតាងទាំងឡាយ ដែលពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទអៀង សារី ដែលតំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញចំពោះមុខអង្គជំនុំជម្រះកន្លងមកនេះ។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សួស្តីតំណាងអយ្យការ សួស្តីសហភាតា ហើយសួស្តីលោកអ្នកទាំងឡាយដែលចូលរួមក្នុងសវនាការនេះ។

ខ្ញុំមានការសង្កេត និងការកត់សម្គាល់មួយចំនួនតូចទេ។ ទី១ យើងបានរក្សាគោលជំហរក្នុងការជំទាស់ទៅលើឯកសារមួយចំនួនដែលសហភាតារបស់ខ្ញុំ លោក ម៉ៃខល កាណាវាស បានលើករួចហើយ គឺយើងជំទាស់ឯកសារជាប្រភេទ មិនមែនជំទាស់ទៅលើឯកសារជាក់លាក់ណាមួយទេ។ ទី២ យើងកត់សម្គាល់ឃើញថា ព្រះរាជអាជ្ញាបាន -- ខ្ញុំក៏បានលើករួចមកហើយ តែសូមលើកម្តងទៀត បានលើកយកភស្តុតាង ឬឯកសារមួយចំនួនមកគាំទ្រអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មទៅវិញ មិនមែនទាក់ទងតែទៅលើតួនាទីរបស់ជនជាប់ចោទេ។

[១០:១០:១០]

ចំណុចចុងក្រោយខ្ញុំកត់សម្គាល់ ហើយក៏ជំទាស់បន្ថែមទៀតក្នុងការដែលព្រះរាជអាជ្ញាព្យាយាម

លើកយកចម្លើយនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលបានស្លាប់ទៅហើយនោះ យកមកប្រើប្រាស់។ ឧទាហរណ៍ដូចជា សាក្សី ថា សុត ជាដើម។ ព្រោះសាក្សី ថា សុត នេះបានស្លាប់ទៅហើយ ហើយភរិយារបស់គាត់ឈ្មោះ ស សៀក នេះក៏បានអះអាងនៅក្នុងសវនាការគាត់ដែរ ថាគាត់មិនដែលបានឮពីស្វាមីរបស់គាត់ ថា សុត ហ្នឹងបាននិយាយប្រាប់គាត់ពីអ្វីដែលលោក ដែលគាត់បានធ្វើនោះនៅក្នុងអង្គាល់គាត់កាន់កិច្ចការនៅជំនាន់នោះ។ នេះជាការកត់សម្គាល់ និងជាការតវ៉ាបន្ថែមរបស់យើង។ ក្នុងករណីដែលយើងយកសម្តី ឬចម្លើយ ឬកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានស្លាប់ទៅហើយនោះ យកមកប្រើ គឺយើងអត់មានភាគី ជាពិសេសខាងមេធាវីមិនមានឱកាសនឹងយកឯកសារនោះមកដេញដោលអ្នកឆ្លើយ ម្ចាស់ឯកសារសាមីខ្លួនដែលបានស្លាប់ទៅហើយទេ។ ដូច្នេះ គួរតែដកឯកសារប្រភេទនេះចេញ បន្ថែមពីអ្វីដែលយើងបានលើកពីមុនរួចហើយ។ សូមអរគុណ។

[១០:១១:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការធ្វើអត្ថាធិប្បាយ ឬក៏នឹងជំទាស់ទៅនឹងបណ្តាឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ដែលដាក់បង្ហាញដោយតំណាងសហព្រះរាជអាជ្ញាកន្លងមកនេះ។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំមានការអត្ថាធិប្បាយមួយចំនួនទៅលើការបង្ហាញឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធជាពិសេសទៅនឹងតួនាទីរបស់លោក ខៀវ សំផន។

[១០:១២:៣៣]

ខ្ញុំសូមរំឭកថា ការបង្ហាញឯកសារគន្លឹះនៅក្នុងដំណាក់កាលនេះ គឺថាជាការលំបាកណាស់ ពីព្រោះថា យើងមិនទាន់បញ្ចប់សវនាការ ហើយយើងក៏មិនទាន់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះដែរ។ ដូច្នេះវាជាការលំបាកបន្តិចហើយរវាងការបង្ហាញឯកសារនេះ និងការបញ្ចប់សវនាការ។ លោក កូប៉េ កាលពីសប្តាហ៍មុននោះ គាត់បានបញ្ជាក់ថា ពាក្យពេចន៍ដែលប្រើដោយសហព្រះរាជអាជ្ញា ស្ទើត នោះគឺថាវាពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារផង ការសន្និដ្ឋានបញ្ចប់ផង។

ដូច្នេះពាក្យពេចន៍របស់គាត់នោះ គឺថាជនជួនកាលទៅវាអាចស្មើទៅនឹងការសន្និដ្ឋានបញ្ចប់ចុងក្រោយផងដែរនោះ។ ចំណុចទាំងអស់នេះ គឺថាមានលក្ខណៈសំខាន់ណាស់ ក៏ប៉ុន្តែខ្ញុំមិនអាចបន្ទោសទៅលើការលំបាកក្នុងការបង្ហាញឯកសារ ហើយនិងការងាកចេញអំពីប្រធានបទរបស់យើងនោះទេ។

ខ្ញុំសូមបញ្ជាក់ម្តងទៀតថា អ្វីដែលខ្ញុំអាចនិយាយបាននៅថ្ងៃនេះនោះ គឺថាការអត្ថាធិប្បាយរបស់ខ្ញុំមានលក្ខណៈរឹតត្បិត ពីព្រោះខ្ញុំមិនចង់ឲ្យវាក្លាយទៅជាសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះទេ។ ខ្ញុំគ្រាន់តែធ្វើការកត់សម្គាល់ជាទូទៅមួយចំនួនតែប៉ុណ្ណោះ។

ការកត់សម្គាល់ទី១របស់ខ្ញុំ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយ គឺនៅពេលដែលខ្ញុំនិយាយអំពីព្រះរាជលិខិតរបស់បរមសព នៃព្រះករុណាព្រះបាទសម្តេចនរោត្តម សីហនុ ដែលលើកឡើងដោយលោកសហព្រះរាជ អាប់ឌុលឡាក់ ខ្ញុំគិតថា វាហួសពេល វាយឺតពេលរួចបន្តិចទៅហើយដែលសហ -- ការិយាល័យសហព្រះរាជអាជ្ញាបានរកឃើញឯកសាររបស់សម្តេចព្រះ នរោត្តម សីហនុ ថាយើងឃើញថាមានការសំខាន់នោះ។ យើងបានបង្ហាញវីដេអូជាច្រើនដែលមានការសម្ភាស ហើយនិងមានចម្លើយរបស់សម្តេច នរោត្តម សីហនុ ដូច្នេះនៅពេលនេះវាហួសពេលហើយ យើងមិនអាច -- ដូចថា វាហួសពេលទៅហើយដែលថាយើងអាចសួរសំណួរទៅកាន់ព្រះអង្គនោះ ព្រោះថា នេះវាហួសពេលហើយ។ នេះគឺជាការកត់សម្គាល់ទី១របស់ខ្ញុំ។

[១០:១៤:៥២]

យើងមានឯកសារជារឿងមួយផ្សេង ហើយយើងមានការសម្ភាសជារឿងមួយផ្សេងទៀត ហើយនៅការដេញដោលនៅក្នុងសវនាការនេះ ជារឿងផ្សេង។

ការកត់សម្គាល់ទី២របស់ខ្ញុំ គឺថា សូមកត់សម្គាល់ថា នៅក្នុងបទបង្ហាញឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់លោកខៀវ សំផន ជាពិសេសឯកសារពាក់ព័ន្ធទៅនឹងវិស័យពាណិជ្ជកម្មនោះ គឺបានបង្ហាញឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយសង្ខេបៗ។ ដូច្នេះ ខ្ញុំពិបាកនឹងធ្វើការកត់សម្គាល់ស៊ីជម្រៅណាស់ ព្រោះថាការបង្ហាញបែបហ្នឹងវាមានលក្ខណៈសង្ខេបពេក ហើយមានការបង្ហាញអំពីសក្ខីកម្មរបស់សាក្សី សគឹម ល្មុត ដែលព្រះរាជអាជ្ញាបានយោងនោះ។ ពេលនោះគឺថា យើងបានសួរឲ្យ គាត់ធ្វើបទអត្ថាធិប្បាយទៅលើតួលេខមួយចំនួន។ ករណីនេះក៏ដូចគ្នាដែរ ខ្ញុំមិនអាចធ្វើការអត្ថាធិប្បាយស៊ីជម្រៅបានទេ ពីព្រោះថា សវនាការនេះវាមានលក្ខណៈរឹតត្បិត ពីព្រោះថាខ្ញុំមិន -- បើខ្ញុំនិយាយច្រើនពេកទៅ វាក្លាយទៅជាសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលទៅវិញ។

[១០:១៦:១៦]

ការកត់សម្គាល់ទី៣ នៅក្នុងដំណាក់កាលនេះ គឺខ្ញុំចង់បញ្ជាក់ជូននូវអ្វីដែលសហមេធាវីនាំបាន បញ្ជាក់ គឺថាឯកសារមានសារៈសំខាន់ មានខ្លឹមសារបាននោះ ទាល់តែមានការប្រឈមមុខទៅនឹង សាក្សី។ ដូច្នេះ ទាល់តែមានសាក្សីមកបង្ហាញសក្ខីកម្មនៅពេលខាងមុខនោះ ទើបយើងអាចមើលឃើញ អំពីខ្លឹមសារនៃឯកសារទាំងអស់នោះបាន។ យើងសូមជំទាស់ទៅនឹងចម្លើយរបស់សាក្សីដែលស្លាប់ ឬក៏ អវត្តមាន។ ដូច្នេះខ្ញុំត្រឡប់មកនិយាយអំពីអត្ថបទរបស់លោក ប៉ែន យៀរនិន ដែលគាត់មិនចង់មកធ្វើ សក្ខីកម្មនោះទេ។ ដូច្នេះការដែលយើងធ្វើការបង្ហាញអំពីឯកសារគន្លឹះបែបនេះ ធ្វើឱ្យខ្ញុំមានការស្រឡាំង កាំងបន្តិចហើយ។ យើងមិនអាចធ្វើការអត្ថាធិប្បាយវែងឆ្ងាយបានទេ ពីព្រោះថាវានាំឱ្យវាក្លាយទៅជា សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

ចំណុចចុងក្រោយរបស់ខ្ញុំនោះគឺពាក់ព័ន្ធទៅនឹងឯកសារជាក់លាក់មួយ គឺឯកសារនោះលើក ឡើងអំពីបញ្ហាដែលយើងអាចរកឃើញនៅក្នុងឯកសារផ្សេងៗទៀត ដែលវាគឺជាការ បញ្ហានៃការបក ប្រែ ដែលបណ្តាលឱ្យមានការយល់អត្ថន័យច្រឡំ។ ខ្ញុំសូមយោងជាក់លាក់ទៅលើឯកសារ E3/165 ឯកសារនេះត្រូវបានអានជាភាសាអង់គ្លេសដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ ហើយក្នុងឯកសារនោះ គឺមានបញ្ជាក់ថា មានសុន្ទរកថារបស់លោក ខៀវ សំផន។ ដើម្បីឱ្យច្បាស់ទាំងអស់គ្នានោះ ខ្ញុំសូមយើង ពិនិត្យមើលទៅលើអ្វីដែលសហព្រះរាជអាជ្ញាបានបង្ហាញកាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣។ ខ្ញុំសូម យោងទៅលើប្រតិចារឹកសវនាការជាភាសាបារាំងនៅមុនម៉ោង១០:១៥ នាទីបន្តិច លោកសហព្រះរាជ អាជ្ញាគាត់បានបង្ហាញថា ឯកសារហ្នឹងមានភាពពាក់ព័ន្ធទៅនឹងសកម្មភាពរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបង្កើតរដ្ឋថ្មី គឺឯកសារ E3/165 ឯកសារដែលយើងបានបង្ហាញរួចមកហើយ។

[១០:១៨:៥៨]

ចុះក្រោមមកបន្តិចមកទៀតក្រោយម៉ោង ១០:១៥នាទី សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារហ្នឹងមានច្រើនណាស់ ហើយខ្ញុំសូមលើកតែមួយផ្នែកទេ ដែលក្នុងនោះយើងរកឃើញសុន្ទរកថា របស់លោក ខៀវ សំផន។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមយោងទៅលើឯកសារនោះតែម្តង ដើម្បីឱ្យច្បាស់ទាំងអស់គ្នា ហើយក្នុង នោះគឺភាសាអង់គ្លេស ដែលសហព្រះរាជអាជ្ញាយោងនោះ មិនមែនជាការបកប្រែរបស់ អ.វ.ត.ក ទេ វាជាការបកប្រែដែលផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដើម្បីឱ្យការបង្ហាញ ការអន្តរាគមន៍

របស់ខ្ញុំច្បាស់លាស់នោះ ខ្ញុំសូមបង្ហាញជាឯកសារបកប្រែរបស់ ឌី.ស៊ី.ខេម ហើយនិងបន្ទាប់មកយើងខ្ញុំនឹងបង្ហាញពីអ្វីដែលយើងមាននៅក្នុងការបកប្រែជាភាសាបារាំង ដែលឯកសារបារាំងនេះបកចេញពីច្បាប់ដើមជាភាសាខ្មែរ ហើយបន្ទាបមកទៀត ខ្ញុំសូមជំនួយពីលោក គង់ សំអុន ឲ្យគាត់អានឯកសារច្បាប់ដើមជាភាសាខ្មែរតែម្តង ដើម្បីឲ្យយើងទាំងអស់គ្នាបានដឹងច្បាស់។

[១០:២០:១៨]

ឯកសារនេះគឺឯកសារ E3/165 សម្រង់ដែលខ្ញុំចង់ទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះនោះ នៅ ERN ជាភាសាអង់គ្លេស 00184048។ នេះគឺជាមាតិកានៃឯកសារ ដែលមានចំណងជើងជាភាសាបារាំង គឺថាចំណងជើងជាភាសាបារាំងនោះ វាត្រូវគ្នាជាមួយនឹងឯកសារខ្មែរតែម្តង គឺឯកសារស្តីអំពីអង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជាថ្ងៃ១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។

នៅក្នុងមាតិកាជាភាសាអង់គ្លេស ដែលអានឡើងដោយសហព្រះរាជអាជ្ញា ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស "សុន្ទរកថារបស់ប្រធានគណៈប្រធានរដ្ឋក្នុងឱកាសបើកអង្គសន្និបាតលើកទី១ ក្នុងសម័យកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជា"។ ជាភាសាបារាំង -- ជាភាសាខ្មែរយើងនោះគឺថាយើងមិន -- ជាភាសាបារាំងនោះគឺយើងបកថា "សុន្ទរកថារបស់ប្រធានគណៈអធិបតីបើកអង្គសន្និបាតលើកទី១ក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជា"។

[១០:២២:១៣]

ដូច្នេះដើម្បីឲ្យច្បាស់ទាំងអស់គ្នាថា យ៉ាងម៉េចនេះសូមឲ្យលោក គង់ សំអុន អានជាភាសាខ្មែរដែលមានលេខ ERN 0053604, (សូមទោស) 606, សូមឲ្យលោក គង់ សំអុន គាត់ឡើងអានពីចំណុចនេះ។ សូមអរគុណ។

សូមអភ័យទោសលោកប្រធាន លោក លេខ ERN របស់ខ្ញុំអម្បាញ់មិញនេះគឺខុសទេ គឺ 00053604។

**លោក គង់ សំអុន៖**

ខ្ញុំសូមអនុញ្ញាតអានជូននូវចំណុចដែលពាក់ព័ន្ធ ដែលសហមេធាវីអន្តរជាតិបានលើកអម្បាញ់មិញនេះ។ នៅក្នុងសេចក្តីបញ្ជាក់នេះគឺថាឯកសារមានលេខ E3/165 ចំណងជើងឯកសារដូចបានរៀបបញ្ជាក់ជូនរួចហើយគឺ ឯកសារស្តីអំពី "អង្គប្រជុំសន្និបាតលើកទី១ក្នុងសម័យកាល ក្នុងកាលសម័យទី១

របស់សភាតំណាងប្រជាជនកម្ពុជាថ្ងៃទី១១ ទៅ ១៣ ខែមេសា ឆ្នាំ១៩៧៦"។ ក្នុងឯកសារនេះ យើងឃើញថានៅក្នុងចំណងជើង បញ្ជាក់ដូចលោកអ្នកស្រីមេធាវីបញ្ជាក់អំមិញគឺថាមានការបកប្រែខុស ហើយខ្ញុំសូមអានជូនចំណុចនេះគឺថា ខ្ញុំសូមអានជូនទាំងអស់តែម្តងគឺ "សុន្ទរកថារបស់ប្រធានគណៈអធិបតី"។

[១០:២៤:១០]

នៅក្នុងនេះគឺថាប្រធានគណៈអធិបតីនេះ នៅពេលដែលធ្វើការប្រែ គឺបកប្រែទៅជាគណៈប្រធានរដ្ឋ។ អ៊ីចឹងហើយបានជាឲ្យមានការច្រឡំ ក៏ប៉ុន្តែចំណុចនេះគឺថាអាចបកស្រាយបញ្ជាក់នៅក្នុងឯកសារដដែលហ្នឹងឡើងវិញ គឺបើយើងមើលទៅលេខ ERN ជាភាសាខ្មែរ 00053610 គឺបានសរសេរយ៉ាងពេញៗតែម្តងគឺថា សុន្ទរកថារបស់ប្រធានគណៈ -- (សូមទោស) សុន្ទរកថារបស់ប្រធានគណៈអធិបតីបើកអង្គប្រជុំសន្និបាតលើកទី១ក្នុងកាលសម័យទី១របស់សភាតំណាងប្រជាជនកម្ពុជា។ ដូច្នេះក្នុងមាតិកាគឺសរសេរអត់អស់ទេ សរសេរត្រឹមតែសុន្ទរកថារបស់ប្រធានគណៈអធិបតី ប៉ុន្តែនៅក្នុងខ្លឹមសារពន្យល់នៅក្នុងទំព័រទី៩នៃអង្គ -- អង្គប្រជុំកំណត់ហេតុអង្គប្រជុំហ្នឹងគឺបញ្ជាក់ពេញតែម្តង។ អ៊ីចឹងយើងអាចមើលឃើញច្បាស់ហើយ កំហុសនេះគឺយើងអាចបញ្ជាក់ដោយក្នុងឯកសារតែមួយនេះតែម្តងបាទ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេះ**

បន្ទាប់ទៅទៀតនោះគឺថានៅក្នុងឯកសារដដែលនោះគឺថាមានកំហុសដដែល កំហុសដូចគ្នា ដូចទៅនឹងអម្បាញ់មិញហ្នឹង គឺថានៅ ERN ជាភាសាអង់គ្លេស 00184051 ដែលមានការបញ្ជាក់ជាភាសាអង់គ្លេស គឺមានន័យថាការអញ្ជើញគណៈប្រធានរដ្ឋឲ្យឡើងមានយោបល់។ ក៏ប៉ុន្តែ ERN ជាភាសាបារាំងនោះ គឺនៅ 00301338 ជាភាសាបារាំងបានបញ្ជាក់យ៉ាងច្បាស់ថា អញ្ជើញប្រធានគណៈអធិបតីឡើងវេទិកាកិត្តិយស។ ហើយជា នៅ ERN ជាភាសាខ្មែរច្បាប់ដើមនោះគឺ 00053609 គឺពាក្យត្រឹមត្រូវក្នុងនេះ យើងឃើញហើយ គឺគណៈអធិបតីទេ អញ្ជើញគណៈអធិបតីឡើងឡើងលើវេទិកាកិត្តិយស។

[១០:២៧:០៣]

ហើយកំហុសម្តងទៀតនៅក្នុងឯកសារដដែលនេះគឺនៅផ្នែកទី៣ ERN ជាភាសាអង់គ្លេស 00184052 នៅក្នុងការបកប្រែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ មានបញ្ជាក់ថាសុន្ទរកថារបស់ប្រធានគណៈប្រធានរដ្ឋក្នុងឱកាសបើកសន្និបាតលើកទី១ នៃសម័យកាលទី១នៃសភាតំណាងប្រជាជន

កម្ពុជា។ ហើយនៅក្នុងឯកសារភាសាបារាំងដែលបកចេញពីភាសាច្បាប់ដើមនោះ នៅ ERN 0030 1339 គឺបានបញ្ជាក់យ៉ាងច្បាស់ថា សុន្ទរកថារបស់ប្រធានគណៈអធិបតីបើកអង្គសន្និបាតលើកទី១ ក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជា។ ហើយ ERN ជាភាសាខ្មែរនោះគឺ 00053 610។ ដូច្នេះនៅពេលដែលយើងបង្ហាញឯកសារទាំងបីនោះទៅ យើងឃើញមានពាក្យថា គណៈប្រធានរដ្ឋនៅក្នុងការបកប្រែជាភាសាអង់គ្លេស ដែលបកប្រែខុសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយធ្វើឲ្យមានការភ័ន្តច្រឡំ ដែលយល់ថា នេះជាសុន្ទរកថារបស់គណៈប្រធានរដ្ឋ ប៉ុន្តែតាមពិតទៅគឺជាសុន្ទរកថារបស់ប្រធានគណៈអធិបតី បើកអង្គសន្និបាតលើកទី១ ក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជា។

[១០:២៨:៥៤]

ដូច្នេះយើងខ្ញុំនឹងធ្វើសំណើទៅផ្នែកបកប្រែរបស់តុលាការ ដើម្បីឲ្យកែប្រែនូវកំហុសជាភាសាអង់គ្លេសនេះ។ នេះជាចំណុចសំខាន់ណាស់ ហើយយើងក៏អាចឃើញកំហុសនេះនៅក្នុងឯកសារផ្សេងៗទៀតផងដែរ នៅពេលដែលយើងលើកឡើងអំពីឯកសារនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ដូច្នេះយើងសូមលើកនូវចំណុចនេះ ពីព្រោះថាវាមានបញ្ហាផ្នែកខ្លឹមសារ ហើយនិងអាចចោទថាអ្នកនេះជាអ្នកនិយាយ អ្នកនោះ។ ដូច្នេះនេះជាអ្វីដែលខ្ញុំចង់លើកឡើងនៅថ្ងៃនេះ។ ខ្ញុំមិនមានចំណុចផ្សេងទៀតដែលត្រូវនិយាយនោះទេ បើសិនជាខ្ញុំនិយាយវែងឆ្ងាយទៅ វានាំឲ្យក្លាយទៅជាសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ ដូច្នេះខ្ញុំនឹងពឹងទៅខាងផ្នែកបកប្រែ ដើម្បីឲ្យជួយពាក់ព័ន្ធទៅនឹងបញ្ហាដែលខ្ញុំបានលើកឡើងនេះ ក៏ប៉ុន្តែខ្ញុំនិយាយអំពី ERN អម្បាញ់មិញនេះគឺថាច្បាស់លាស់ហើយ។ អ៊ីចឹងយើងអាចឃើញថាមានកំហុសទាំងអស់គ្នាហើយ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយទៅមេធាវី អង់តា ហ្គីសសេ។ លោកស្រីមេធាវីតើលោកស្រីមានដាក់សំណើទៅផ្នែកបកប្រែហើយឬនៅ ដើម្បីកែប្រែនូវកំហុសបកប្រែដែលលោកស្រីយល់ថាខុសនៅក្នុងឯកសារនេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

យើងខ្ញុំមិនទាន់បានបង្ហាញនៅឡើយទេ ពីព្រោះថា យើងធ្វើការនៅក្នុងក្រុមរបស់យើង ពាក់ព័ន្ធទៅនឹងឯកសារខ្មែរ ហើយឯកសារបារាំង។ ហើយនៅពេលស្ដាប់ឮនូវការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះ ទើបយើងអាចរកឃើញនូវកំហុសពាក់ព័ន្ធនឹងការបកប្រែនេះ។ យើងខ្ញុំជម្រាបអង្គជំនុំជម្រះថា យើងខ្ញុំនឹងធ្វើសំណើទៅផ្នែកបកប្រែ។ ដោយសារការដែលយើងមិនបានធ្វើសំណើនោះ គឺថាយើងទើបតែឃើញកំហុសនាពេលថ្មីៗនេះទេ។

[១០:៣១:១៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សំណួរមួយទៀតដែលខ្ញុំចង់សួរលោកស្រីនោះ គឺពាក់ព័ន្ធទៅនឹងសញ្ញាណនៃប្រធានគណៈអធិបតី។ បើតាមលោកស្រីនោះ តើមានឯកសារណាមួយដែលមានបញ្ជាក់អំពីមុខងាររបស់ប្រធានគណៈអធិបតីដែរឬទេ? ខ្ញុំមិនដឹងថា តើមុខងារប្រធានគណៈអធិបតីនេះមានន័យយ៉ាងម៉េចទេ ហើយមិនដែលឃើញមានឯកសារណាបង្ហាញអំពីមុខងាររបស់ប្រធានគណៈអធិបតីនោះទេ? ដូច្នេះ ខ្ញុំមិនដឹងថាកំហុសនេះវាត្រឹមត្រូវដែរឬទេ ឬក៏អត់នោះទេ។

[១០:៣១:៣៤]

*(មានបញ្ហាបច្ចេកទេស)*

*(សវនាការសម្រាកពីម៉ោង ១០:៣១នាទី ដល់ម៉ោង ១១:១៣នាទី)*

[១១:១៣:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដំណើរការសវនាការចុងក្រោយអម្បាញ់មិញនេះ មានបញ្ហាឧបករណ៍ថតសំឡេង ហើយមានការរៀបចំសាឡើងវិញ អ៊ីចឹងហើយបានជាមានការយឺតយ៉ាវក្នុងការចូលមកបន្តកិច្ចដំណើរការសវនាការ។ ហើយម្យ៉ាងទៀត ការបាត់សំឡេងឆ្លើយតបរបស់មេធាវីជាតិការពារក្ដីលោក ខៀវ សំផន នូវសំណួរចុងក្រោយ ដែលតបឡើងដោយ -- អ៎! ដែលសួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ ដូច្នេះ សូមលោកមេធាវីការពារក្ដីបំភ្លឺតាំងពីដើមដំបូងនៃ

ដើម្បីតបទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ បាទ -- លោកមេធាវីជាតិ ការពារក្តីលោក ខៀវ សំផន។

[១១:១៤:២៨]

**លោក គង់ សំអុនៈ**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំសូមអនុញ្ញាតឆ្លើយតបសាជាថ្មី ចាប់ពីដំបូងមក គឺថាសំណួររបស់លោកចៅក្រម ឡាវែន៍ ថាតើប្រធានគណៈប្រតិភូនោះជានរណា? ហើយខ្ញុំនឹងលើកបញ្ជាក់បន្ថែមទៅអ្វីដែលបានឆ្លើយ រួចហើយ។ ដូចថា នៅក្នុងឯកសារ E3/165 នេះ ដោយមានការបកប្រែច្រឡំ ចំពោះពាក្យថា “ប្រធានគណៈអធិបតី” ទៅជា “ប្រធានគណៈប្រធានរដ្ឋ”។ ហេតុនេះហើយបានជាមានចំណោទនេះកើតឡើង។

នៅក្នុងភាសាខ្មែរបានបញ្ជាក់ហើយថា សុន្ទរកថា ខ្ញុំសូមអានជូន “សុន្ទរកថារបស់ប្រធានគណៈអធិបតី។ បើកអង្គប្រជុំសន្និបាតលើកទី១ ក្នុងកាលសម័យទី១របស់សភាតំណាងប្រជាជនកម្ពុជា”។ នៅក្នុងចំណុចនេះ បានបញ្ជាក់នៅក្នុងខ្លឹមសារក្នុងទំព័រ៩ លម្អិតអំពីសេចក្តីថ្លែងការណ៍នោះ។ ដោយឡែកទៀត យើងឃើញថា នៅក្នុងរបាយការណ៍នេះបានបញ្ជាក់អំពីសេចក្តីប្រកាសបិទពិធី និងសេចក្តីបញ្ជាក់ថែមរបស់ប្រធានគណៈអធិបតី។ “សេចក្តីប្រកាសបិទពិធី និងសេចក្តីបញ្ជាក់បន្ថែមរបស់ប្រធានគណៈអធិបតី” ដែលមាននៅក្នុងលេខ ERN ឯកសារដដែល ERN ជាភាសាខ្មែរ 0053628 (សូន្យបីដង បាទ) ហើយដល់ 29 ហើយជាភាសាបារាំង គឺ 00301350, ជាភាសាអង់គ្លេស 00184063។

[១១:១៧:០៥]

នៅក្នុងនេះប្រធានគណៈអធិបតីនោះ បានបញ្ជាក់អំពីរបៀបវារៈនៃអង្គប្រជុំសន្និបាតលើកទី១ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជា។ ដែលនៅក្នុងរបៀបវារៈនេះ មាន៩ចំណុច ក៏ប៉ុន្តែនៅក្នុងចំណោមនោះ យើងចាប់អារម្មណ៍នៅលើចំណុចទី៥ ដែលបញ្ជាក់ “អំពីការជ្រើសតាំងគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ”។ ដូច្នេះ ការជ្រើសតាំងគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ គឺទើបតែចាប់ផ្តើមនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ នោះទេ។ ហើយការបើកសម័យប្រជុំនេះ គឺតាំងពីថ្ងៃទី១៣ គឺ១ថ្ងៃមុន បាទ។

អ៊ីចឹង ខ្ញុំសូមជម្រាបជូនប៉ុណ្ណឹង បញ្ជាក់ថាកំហុសនៃការបកប្រែ និងទី២ គឺថាប្រធានគណៈ

ប្រធានរដ្ឋ គឺមិនមែនជាអ្នកធ្វើសេចក្ដីប្រកាសបើកអង្គប្រជុំមហាសន្និបាតលើកទី១ ក្នុងសម័យ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជានោះទេ។ ហើយក្នុងនេះ បើសិនជាតុលាការចង់ដឹងថានរណាជាអ្នកធ្វើសេចក្ដីប្រកាសនេះ អាហ្នឹងគឺខាងតំណាងអយ្យការជាអ្នកមានតួនាទីក្នុងការបង្ហាញភស្តុតាង បញ្ជាក់ថាជានរណានោះ បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ជាបន្ត អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសឆ្លើយតបទៅនឹងសេចក្ដីជំទាស់ ឬក៏ការធ្វើអត្ថាធិប្បាយរបស់មេធាវីការពារក្ដី។

[១១:១៩:០៥]

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី ហើយនិងភាគីសាធារណជន។ សហព្រះរាជអាជ្ញាមានចម្លើយតបដោយខ្លីអំពីសេចក្ដីសង្កេត ដែលធ្វើឡើងដោយទាំងក្រុមរបស់លោក អៀង សារី ទាំងក្រុមការពារលោក ខៀវ សំផន។ អ៊ីចឹងខ្ញុំឆ្លើយតបទៅនឹងសេចក្ដីសង្កេតធ្វើឡើងដោយក្រុមមេធាវីការពារក្ដីលោក អៀង សារី នោះ។

ទី១ លោក លោកស្រីចៅក្រម ដូចដែលលោកជ្រាបហើយ គោលបំណងនៃសវនាការនេះ គឺបង្ហាញអំពីតម្លៃងភស្តុតាងនៃវត្ថុតាងទាំងអស់ ដែលបានដាក់ជូនទៅតុលាការ។ ជាពិសេស ដើម្បីជាសាធារណជនជ្រាប ដើម្បីឲ្យលោក លោកស្រីចៅក្រមបានជ្រាប ហើយគោលបំណងនៃសវនាការនេះគឺមិនមែនដើម្បីលើកបញ្ហាអំពីការទទួលយកឯកសារនោះទេ។ ឯកសារដែលបានយោងទៅលើដោយសហព្រះរាជអាជ្ញា គឺតុលាការបានទទួលហើយ នៅក្នុងសេចក្ដីសម្រេចខែមិថុនា ឆ្នាំ២០១២។ ដូច្នេះយោបល់ ដោយក្រុមមេធាវីការពារក្ដីលោក អៀង សារី ដែលថារក្សាសិទ្ធិក្នុងការជំទាស់ចំពោះប្រភេទឯកសារមួយចំនួន អំពីភាពអាចទទួលយកបាននោះ គឺថាសិទ្ធិបែបនេះ គឺមិនអាចរក្សាបាន មិនអាចរក្សាទុកបានទេ ពីព្រោះសេចក្ដីសម្រេចតុលាការបានធ្វើរួចទៅហើយ។ ទាក់ទងសេចក្ដីសង្កេត ដែលធ្វើឡើងដោយសេចក្ដីថ្លែងការណ៍ដែលសហព្រះរាជអាជ្ញាបានប្រើនោះ គឺដូចជាចម្លើយរបស់ ថា សុត ដែលថាគាត់បានស្លាប់ហើយ សាក្សីនោះ។

ជាថ្មីម្ដងទៀត គឺត្រូវបានអនុញ្ញាតដោយតុលាការ នៅក្នុងសេចក្ដីសម្រេចដើម្បីឲ្យប្រើចម្លើយ

របស់បុគ្គលដែលបានស្លាប់នៅក្នុងដំណើរការនីតិវិធី ប៉ុន្តែផ្ទុយទៅវិញ ចម្លើយនោះគឺយើងមិនបានប្រើនៅក្នុងបទបង្ហាញឯកសារដែលទាក់ទងនឹងលោក អៀង សារី ទេ។

[១១:២១:០១]

ចំណុចទទី២ ៗ សំខាន់ដែលមេធាវីការពារក្តីលោក អៀង សារី លើកឡើងនោះ គឺថាសេចក្តីសន្និដ្ឋាន ដែលលើកឡើងដោយសហព្រះរាជអាជ្ញានោះ ថាមិនពាក់ព័ន្ធក្នុងការបង្ហាញភស្តុតាង អំពីតួនាទីរបស់ជនជាប់ចោទ។ ដូច្នេះ ខ្ញុំសូមជម្រាបថា ការលើកបែបនោះ គឺមិនត្រឹមត្រូវទេ។ អ្វីដែលសហព្រះរាជអាជ្ញាដែលបានលើកឡើង គឺឯកសារមួយចំនួនទាក់ទងអំពីតួនាទីរបស់គាត់ តួនាទីរបស់លោក អៀង សារី។ ហើយក្នុងការធ្វើបែបនោះ គឺយើងមានចេតនាដើម្បីគាំទ្រជំហរប្រាំដែលទាក់ទងនឹងតួនាទីរបស់គាត់។ ទី១ គឺថាតើគាត់មានតួនាទីអ្វី នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ? ទី២ ជំហរនោះគឺថាតើអ្វីកម្រិតអំណាចណាដែលគាត់មាននៅក្នុងគណៈអចិន្ត្រៃយ៍ ហើយនិងនៅក្នុងក្រសួងការបរទេស? ជំហរទី៣ នោះ គឺថា តើគាត់បានចូលរួមនៅក្នុងគណៈអចិន្ត្រៃយ៍ក្នុងកម្រិតណា? ហើយនៅក្នុងក្រសួងការបរទេសនោះ ក្នុងកម្រិតណា? ជំហរទី៤ របស់សហព្រះរាជអាជ្ញានោះ គឺថាតើគាត់ចូលរួមញឹកញាប់ប៉ុនណា ដើម្បីឱ្យយល់អំពីតួនាទីរបស់គាត់ ទំហំប៉ុនណា។ ជំហរចុងក្រោយ ថាតើសារធាតុ ខ្លឹមសារ តើគោលបំណងនៃតួនាទីរបស់គាត់នោះ ត្រឹមណា? គឺមិនត្រឹមតែតួនាទីនោះទេ ថាតើសកម្មភាពការងារដែលគាត់អនុវត្តក្នុងតំណែងនោះ វាអ្វីខ្លះ។

[១១:២២:៣៨]

ដើម្បីបញ្ចប់ពីជំហរនេះ គឺថាសហព្រះរាជអាជ្ញានឹងពិនិត្យមើលតម្លៃភស្តុតាងនៃឯកសារទាំងអស់នេះ ដែលរួមបញ្ចូលនេះ គឺថាដែលបញ្ជាក់ថា តួនាទីរបស់លោក អៀង សារី ជាសារធាតុ ជាសក្តានុពលនោះ គឺថាដើម្បីពង្រឹងនូវដំណើរការ ហើយចូលរួមក្នុងការកសាងនូវសង្គមនិយម កសិករពលករ ពីដំណាក់កាលមួយឱ្យលឿនបំផុត។ ហើយគាត់ជាអ្នកការពារដំណើរការនៃការបង្កើតសង្គមនិយមនោះ ដោយការលុបបំបាត់ ឬក៏សម្លាប់នូវខ្មាំងណា សត្រូវណាដែលពិតក៏ដោយ ឬក៏តាមការសន្និដ្ឋានរបស់បក្សក៏ដោយ ទោះបីជាបក្ស អំ! ខ្មាំងនៅខាងក្នុង ឬខាងក្រៅក្តី។

ដូច្នេះ គឺជាជំហររបស់សហព្រះរាជអាជ្ញាអំពីតួនាទីដ៏សំខាន់របស់គាត់នោះ គឺថាគឺត្រូវបានបង្ហាញពីលក្ខណៈជាតម្លៃភស្តុតាង នៅក្នុងឯកសារដែលយើងខ្ញុំបានបង្ហាញ។ ហេតុការណ៍ដែលថាឯកសារនោះ មកពីប្រភពផ្សេងៗ ថាបានផលិតក្នុងពេលខុសគ្នាៗក្តី។ ផែនការដែលបានផលិតនៅក្នុង

សម័យនោះក្តី ហើយអង្គហេតុដែលថាឯកសារនោះ ខាងក្នុងបក្ស ឯកសារសម្ងាត់របស់បក្ស ឬឯកសារក្រៅរបស់បក្ស ដូចជាសុន្ទរកថានៅមហាសន្និបាតនៃអង្គការសហប្រជាជាតិ។ អង្គហេតុដែលថាឯកសារទាំងអស់នោះ បានចង្អុលបង្ហាញទៅលើតួនាទីដដែលនោះ គឺដើម្បីការពាររបបសង្គមនិយមបែបកម្មករ កសិករ ហើយដើម្បីការពារ ទោះបីជាក្នុងករណីណាក៏ដោយ ទោះបីជាត្រូវចំណាយអ្វីក្តី។ ដូច្នេះ ខ្ញុំសូមជម្រាបថា តម្លៃជាភស្តុតាងនៃឯកសារនេះ គឺថាជាឯកសារដែលស៊ីសង្វាក់គ្នា ស្របគ្នាទៅនឹងអង្គហេតុទាំងអម្បាលម៉ាននោះឯង។

[១១:២៤:៤៥]

មេធាវីការពារក្តីបានសម្រេចថាមិនលើកឡើងពីបញ្ហានេះទេ គឺនេះគឺជាបញ្ហារបស់ពួកគាត់ទេ ក៏ប៉ុន្តែខ្ញុំសូមជម្រាបថា ភាពពាក់ព័ន្ធដែលលោក លោកស្រីចៅក្រម ពិនិត្យហើយ គឺទាក់ទងទៅបញ្ហាមិនទាក់ទងថាឯកសារនេះទទួលបាន ឬមិនទទួលបាននោះទេ។ ប៉ុន្តែត្រូវពិនិត្យទៅលើអ្វីដែលថាជាឯកសារដែលពាក់ព័ន្ធ ដើម្បីបង្ហាញអំពីតួនាទីរបស់គាត់។ ហើយសហព្រះរាជអាជ្ញាសូមជម្រាបថា ជាតួនាទី -- ជាឯកសារដែលមានភាពពាក់ព័ន្ធ។ នេះហើយជាសេចក្តីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីរបស់លោក អៀង សារី។

ឥឡូវនេះខ្ញុំនឹងជូនវេទិកាទៅឲ្យលោកថារីក អាប់ឌុលឡាក់ ដើម្បីបន្តការងាររបស់គាត់ចំពោះមុខតុលាការ។

[១១:២៥:៣៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំនឹងឆ្លើយតបដោយសង្ខេបទៅនឹងសេចក្តីសង្កេតរបស់មេធាវីការពារក្តីរបស់លោក ខៀវ សំផន ហើយខ្ញុំនឹងលើកឡើងទៅតាមលំដាប់លំដោយដែលមេធាវីបានលើកឡើងនោះឯង។

មេធាវីបានសម្តែងការខកចិត្តថា ទើបតែពេលនេះទេដែលយើងបានព្យាយាមពឹងផ្អែកលើឯកសារសម្ភារៈ ដែលចងក្រងឡើងដោយព្រះបរមកោដ្ឋ នរោត្តម សីហនុ នោះ។ នេះតាមពិត នេះមិនមែនជាការលើកឡើងត្រឹមត្រូវទេ ពីព្រោះការពិតនោះគឺថាយើងពឹងផ្អែកលើឯកសារនេះតាំងពីចំណុចដើម គឺខែសីហា ឆ្នាំ២០១០ ឯណោះ ដែលជាជំហររបស់យើងគឺថាបន្ទាប់ពីបញ្ចប់នៃការស៊ើបសួរ ហើយយើងមានឯកសារនៅក្នុងវិធាន៨០។ ហើយដូច្នេះហើយយើងបានដាក់បញ្ចូល ហើយយើងបានស្នើនៅក្នុង

បញ្ជីស្នើភស្តុតាងរបស់យើង។

លើសពីនេះទៅទៀត ខ្ញុំបានពិនិត្យមើលនូវសេចក្ដីត្រូវការអំពីការរក្សាការសម្ងាត់នៃឯកសារ ដែលមិនទាន់បានផ្សាយជាសាធារណៈនោះ។ ប៉ុន្តែបើភាគីទាំងអស់នៅក្នុងសាលសវនាការ ហើយអង្គជំនុំជម្រះផងដែរនោះ យោងទៅរកឯកសារ E131.1.1 ហើយជាពិសេស គឺនៅលេខទី២៣ នៅក្នុងតារាងដែលមានឯកសារនេះបាទ។

យើងឃើញច្បាស់ថា ហេតុអ្វីបានថាជាភាពមិនសមស្រប ដើម្បីយើងដាក់ឯកសារចំពោះមុខអង្គតុលាការកាលពីដំហានដំបូងនៃដំណើរការនីតិវិធីនោះ។ ឥឡូវនេះខ្ញុំចូលទៅបញ្ហាទាក់ទងទៅនឹងឯកសារពាណិជ្ជកម្ម ហើយនិងជំនួញរបស់កម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំមិនដឹងថាតើមេធាវីនោះអះអាងថាយើងជ្រៀតនៅក្នុងនីតិវិធី។ ក៏ប៉ុន្តែយើងដាក់នូវឯកសារនូវកំណត់ត្រាដ៏ច្រើន យើងស្រង់តែមួយចំនួនតូច ដែលយើងចង្អុលបង្ហាញថា របាយការណ៍ហ្នឹងគឺត្រូវបានដាក់ជូនជាបន្តបន្ទាប់ដោយក្រសួងពាណិជ្ជកម្មទៅខៀវ សំផន ដូចខ្ញុំបានជម្រាបជូនហើយ គឺមិនតិចជាងរបាយការណ៍២៨នោះទេ ហើយបន្ទាប់ពីនោះគឺថាមានឯកសារ៥០ទៀតរបស់ក្រសួងពាណិជ្ជកម្ម ដែលមានចំណារ ដែលចារជូនទៅលោក ខៀវ សំផន។

[១១:២៨:២២]

គេបានយោងទៅសក្ខីកម្មរបស់សាក្សី សគឹម ល្មុត ដែលមានដាក់លាក់នៅក្នុងទំព័រនោះ ប៉ុន្តែទាក់ទងទៅនឹងបណ្ដាញនោះ គឺថាយើងបាននឹកឃើញហើយនៅក្នុងពេលសម្រាកនោះ គឺថាសាក្សីបានបញ្ជាក់អំពីការងាររបស់ វ៉ាន់ រិត ហើយនិងគាត់ គឺថាគាត់នៅក្រោម វន វ៉េត ក្រោយមកក្រោមលោក ខៀវ សំផន នោះ។ ទាក់ទងទៅនឹងរបាយការណ៍ដែលចងក្រងឡើងដោយលោក ប៉ែន យៀវនិន នោះ គឺមានចំណុចដែលថាវាត្រូវមានការយល់ស្របរវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី ហើយយើងបានស្នើឲ្យលោក ប៉ែន យៀវនិន មកបង្ហាញការពន្យល់នៅក្នុងជាអ្នកជំនាញដល់តុលាការ។ ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចថា មិនកោះអញ្ជើញគាត់ទេ។ ដូច្នេះហើយ ការធ្វើបែបនេះក៏មិនមែនមានន័យថារបាយការណ៍របស់គាត់មិនអាចទទួលយកបាននោះទេ។ នោះជាបញ្ហាដែលអង្គជំនុំជម្រះត្រូវសម្រេចពិចារណាអំពីតម្លៃដែលទាក់ទងទៅនឹងភស្តុតាងនោះ។

[១១:២៩:៤០]

ចំណុចទីបញ្ចប់ និយាយអំពីការអះអាងថា មានការបកប្រែ ឬក៏ភាពខុសគ្នារវាងឯកសារ

E3/165 នោះ តាមពិតយើងខ្ញុំមិនមានចេតនា ដើម្បីយោងទៅរកថាជាសេចក្ដីថ្លែងការណ៍ហ្នឹងធ្វើដោយ ខៀវ សំផន នោះទេ។ យើងបានធ្វើការងារនេះដោយសុច្ឆន្ទៈ យើងបានពិនិត្យឯកសារ។ ដូច្នេះគឺថាតាមពិតគឺមានកំណត់ហេតុមួយចំនួនរបស់សភា ការប្រជុំរបស់រដ្ឋសភានៅក្នុងឆ្នាំ១៩៧៦ របស់កម្ពុជាប្រជាធិបតេយ្យ ហើយយើងចូលរួមជាមួយមេធាវីការពារក្ដី ដើម្បីកែតម្រូវដើម្បីពិនិត្យមក កែសម្រួលអត្ថបទបកប្រែ។ ប៉ុន្តែមេធាវីការពារក្ដីបានកត់សម្គាល់ឯកសារយ៉ាងហោចណាស់ តាំងពីខែកញ្ញា ២០១០ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានយោងទៅក្នុងដីកាដំណោះស្រាយនៅក្នុងបរិបទដូចគ្នាដែលខ្ញុំបានយោងនេះឯង នៅក្នុងអំឡុងពេលនៃការបង្ហាញឯកសារនោះ។ លោក លោកស្រីចៅក្រមមើលកថាខណ្ឌ១១៦៦ នៃដីកាដំណោះស្រាយ នៅក្នុងលេខជើងទំព័រ៧៧១ សហចៅក្រមស៊ើបអង្កេតបានពឹងផ្អែកលើឯកសារនេះ ជាភស្តុតាងដែលបញ្ជាក់ពីសុន្ទរកថារបស់ ខៀវ សំផន នៅក្នុងកថាខណ្ឌ ១១៧៣ នៅក្នុងហ្វូតណូត ៤៧៩៦ សហចៅក្រមស៊ើបអង្កេតបានយោងរកឯកសារនេះ ដើម្បីគាំទ្រសេចក្ដីសន្និដ្ឋាន ដែលតាមពិតគឺលោក ខៀវ សំផន ដែលជាគណៈអធិបតីនៃកិច្ចប្រជុំនោះ។

[១១:៣១:២១]

ឯកសារដំបូង -- ឯកសារដើមដែលយោងនោះគឺថា 13.13 ហើយយើងនឹងស្វែងរកនៅក្នុងដីកាដំណោះស្រាយ ឃើញយោងបែបនេះគឺថាប្រាកដណាស់លោក លោកស្រីចៅក្រម យើងនឹងប្រឹងប្រែងដើម្បីកែតម្រូវកំណត់ត្រា ហើយប្រសិនបើមានកំហុសឆ្គង ហើយយើងនឹងព្យាយាមកែតម្រូវទៅតាមនោះ។ ដូច្នេះហើយជាសុន្ទរកថាមួយចំនួន ដែលយើងបានបង្ហាញចំពោះមុខតុលាការ។ ដូច្នេះហើយគឺមិនមានអ្វីដែលជាសុន្ទរកថាខុសពីការគាំទ្រ ហើយនិងការលើកកម្ពស់គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ។ នេះជាសេចក្ដីឆ្លើយតបដោយសង្ខេបរបស់ខ្ញុំ។ សូមអរគុណតុលាការ។

**ប្រធានអង្គជំនុំ៖**

បាទ មានអ្វីផ្សេងទៀតទេ?

[១១:៣២:២៧]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមត្រឡប់ទៅនិយាយពីអ្វីដែលសហភាតាលើកឡើង -- ពីអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញ គឺថាយើងកំពុងតែពិនិត្យលើតម្លៃភស្តុតាង គឺថាគោលបំណងគឺថាយើងនិយាយអំពីភាពពាក់ព័ន្ធនៃឯកសារ ហើយនិងគឺថានិយាយអំពីតម្លៃនៃភស្តុតាងនោះ និយាយទាល់

តែពេលយើងពិភាក្សាដេញដោលចប់ហើយ ហើយនិងពេលយើងស្តាប់សក្ខីកម្មអស់ហើយ បានយើងអាចនិយាយពីតម្លៃនេះបាន តម្លៃភស្តុតាងនេះបាន។ អ៊ីចឹងខ្ញុំសូមបញ្ចប់អំពីកម្មវត្ថុនៃការពិភាក្សាឯកសារគន្លឹះរបស់យើង នៅក្នុងក្របខ័ណ្ឌនៃសវនាការយើងនេះ។ លោកប្រធាន សូមបញ្ចប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ បាទជាបន្តទៅនេះអង្គជំនុំជម្រះវំឭក ជម្រាបជូនភាគី និងសាធារណជនជ្រាបថា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ លោក នួន ជា បានលះបង់សិទ្ធិក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ ការទទួលយក និងការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានាចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងអង្គហេតុ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ ទីកន្លែងសម្លាប់នៅទួលពោធិ៍ជ្រៃ តួនាទីរបស់ជនជាប់ចោទ និងគោលនយោបាយសហឧក្រិដ្ឋកម្មរួម។ ឯកសារ E258/2។

[១១:៣៣:៥៣]

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ លោក នួន ជា បានដាក់លិខិតមួយមកអង្គជំនុំជម្រះ សូមដកការលះបង់សិទ្ធិរបស់ខ្លួន ឯកសារ E258/3។ អាស្រ័យហេតុនេះអង្គជំនុំជម្រះមិនអាចបន្តធ្វើសវនាការលើការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានាចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ នួន ជា និងគោលនយោបាយសហឧក្រិដ្ឋកម្មរួមបាន ដោយមិនមានវត្តមានជនជាប់ចោទ នួន ជា ឬក៏មានលក្ខខណ្ឌសមស្របដែលនាំឲ្យអង្គជំនុំជម្រះអាចធ្វើសវនាការបាននោះទេ។

នៅរសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ លោក នួន ជា ត្រូវបានចេញពីមន្ទីរពេទ្យ និងបញ្ជូនមកកាន់មន្ទីរឃុំឃាំងអ.វ.ត.ក វិញ។ គ្រូពេទ្យដែលទទួលបន្ទុកព្យាបាលបានផ្តល់អនុសាសន៍ដល់អង្គជំនុំជម្រះថា តម្រូវឲ្យគាត់សម្រាកក្នុងរយៈពេល១៤ថ្ងៃ គិតពីថ្ងៃគាត់ចេញពីមន្ទីរពេទ្យ។ នៅថ្ងៃរសៀលទី៣១ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានស្នើសុំមេធាវីការពារក្តី នួន ជា ឲ្យបញ្ជាក់អំពីជំហរលះបង់សិទ្ធិនៅក្នុងការចូលរួមសវនាការក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសក្សី TCW-100 និង/ឬដើមបណ្តឹងរដ្ឋប្បវេណី TCCP-116។

[១១:៣៥:២៤]

នៅវេលាយប់ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៣ លោក នួន ជា បានមានបញ្ហាសុខភាព ហើយត្រូវបានគ្រូពេទ្យប្រចាំការនៅ អ.វ.ត.ក បញ្ជូនទៅកាន់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីទទួលការ

ព្យាបាល។ បច្ចុប្បន្នលោក នួន ជា បាននិងកំពុងតែដេកសម្រាកទទួលការព្យាបាលនៅឯមន្ទីរពេទ្យ។ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣ លោក នួន ជា តាមរយៈមេធាវីការពារក្តីរបស់គាត់ គាត់បានបង្ហាញជំហរក្នុងការមិនលះបង់សិទ្ធិក្នុងការចូលរួមសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-100 តែគាត់បានបង្ហាញជំហរក្នុងការលះបង់សិទ្ធិ ក្នុងការចូលរួមសវនាការពិភាក្សាដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-116 ហើយការណ៍នេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងសវនាការកាលពីព្រឹកមិញនេះ ដោយក្រុមមេធាវីការពារក្តី នួន ជា។

[១១:៣៦:១៩]

តាមការបញ្ជាក់របស់ប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា ដើមបណ្តឹងរដ្ឋប្បវេណី TCCP-116 និងអាចមានវត្តមាននៅ អ.វ.ត.ក នៅថ្ងៃព្រហស្បតិ៍ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣។ អាស្រ័យហេតុនេះអង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគី និងសាធារណជនថា កាលបរិច្ឆេទកំណត់ធ្វើសវនាការការដាក់ឯកសារគន្លឹះ ដែលតំណាងសហព្រះរាជអាជ្ញាមិនទាន់បានដាក់បង្ហាញចំពោះមុខជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងតួនាទីរបស់គាត់ និងគោលនយោបាយសហឧក្រិដ្ឋកម្មរួម និងបញ្ហាដែលនៅសេសសល់ពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារគន្លឹះនានា អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទធ្វើសវនាការនៅពេលខាងមុខ និងជម្រាបជូនភាគីក្នុងកាលវេលាសមស្របឲ្យបានមុនពេលធ្វើសវនាការ។

ឯសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី TCCP-116 អង្គជំនុំជម្រះកំណត់កាលបរិច្ឆេទធ្វើសវនាការស្តាប់សក្ខីកម្មគាត់នៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

បាទ នេះជា សូមជម្រាបជូនឲ្យបានច្បាស់លាស់នូវបញ្ហាចំពោះមុខ អង្គជំនុំជម្រះ និងការប្រឹងប្រែងដើម្បីរៀបចំនូវកំណត់កាលបរិច្ឆេទ ក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីទៅតាមលទ្ធភាពដែលអាចធ្វើទៅបានក្នុងករណីមានបញ្ហាចំពោះមុខនេះ។

[១១:៣៧:៥៤]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយ ដោយហេតុថាប្រធានបទដែលអង្គជំនុំជម្រះបានកំណត់លើកយកមកធ្វើការពិភាក្សានៅក្នុងសវនាការថ្ងៃនេះ បានធ្វើរួចមុនពេលកំណត់។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការដែល

គ្រោងធ្វើនៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ គឺធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-116 ដែលនឹងផ្ដើមសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្ដី។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ លោក អៀង សារី និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទាប់សវនាការនេះវិញនៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនពីក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១១:៣៩នាទី)*